# កម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម

សំណុំរឿង០០២ ▪របាយការណ៍លេខ៤៣ ▪សវនាការលើកស្ដុតាង ▪សប្ដាហ៍ទី៣៨ ▪១២ និង ១៤ វិច្ឆិកា ២០១២




**Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center**

*(ស្ថានភាពនៅទីក្រុងភ្នំពេញមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥) ខ្ញុំឃើញភ្លើងឆេះសន្ធោសន្ធៅ ហើយយប់ហ្នឹងមានគ្រាប់ផ្លោងធ្លាក់ច្រើន...។ មនុស្សម្នាភ័យគ្រប់គ្នា ភ័យមិនដឹងជាគ្រាប់ធ្លាក់កន្លែងណាទៀត មិនដឹងធ្លាក់ចំកន្លែងខ្ញុំ ឬកន្លែងគេ ហើយខ្ញុំអរដែរបើស្ថានការណ៍ហ្នឹងវាបានបញ្ចប់ លែងមានសភាពភ័យខ្លាចហ្នឹងតទៅទៀត។ ម៉្លោះហើយ ខ្ញុំខ្លួនឯងហ្នឹងគិតថា ស្ថានការណ៍នឹងចប់ក្នុងពេលឆាប់ៗនេះឯង។*[1]

*ដើមបណ្ដឹងរដ្ឋប្បវេណី លោក* ***មាស សារ៉ាន់***

## ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅ

សប្ដាហ៍នេះ អង្គជំនុំជម្រះបានបន្តកិច្ចដំណើរការនីតិវិធីសវនាការពីរថ្ងៃ គឺថ្ងៃចន្ទ និងថ្ងៃពុធ ដោយសារតែនៅថ្ងៃអង្គារ ត្រូវបានគ្រោងទុកសម្រាប់ធ្វើសវនាការលើបណ្ដឹងឧទ្ធរណ៍នៅចំពោះមុខអង្គជំនុំជម្រះនៃតុលាការកំពូល ស្ដីពីការដោះលែងលោកស្រី **អៀង ធីរិទ្ធ** ដោយគ្មានលក្ខខណ្ឌពីមន្ទីរឃុំឃាំង។[2] ជាដំបូង អង្គជំនុំជម្រះសាលាដំបូងបានស្ដាប់នូវការឆ្លើយតបពីភាគីពាក់ព័ន្ធទាំងអស់ ក្រោយពីបានស្ដាប់ហើយ សក្ខីកម្មរបស់វេជ្ជបណ្ឌិត **ចន ខាំប៊ែល** ស្ដីពីស្ថានភាពសុខភាព និងកាយសម្បទាក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទ **អៀង សារី** កាលពីសប្ដាហ៍មុន[3] ដោយសារតែមានការស្នើពីមេធាវីការពារក្ដីរបស់ជនជាប់ចោទ ដែលបានសុំឲ្យអង្គជំនុំជម្រះសាលាដំបូងពន្យារពេលចេញសេចក្ដីសម្រេចលើបញ្ហានេះ។ អង្គជំនុំជម្រះ ក៏បានស្ដាប់សក្ខីកម្មរបស់

សាក្សី គឺលោក **ប៉ែជុយ ជីបសែ** ជាអតីតស្មៀនមួយរូបនៃមន្ទីរសន្តិសុខពង្រ ហើយក៏បានចាប់ផ្តើមស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត គឺលោក **មាស សារ៉ាន់**។ សវនាការនៅសប្តាហ៍នេះ បានយល់ឃើញថា អង្គជំនុំជម្រះបានរៀបចំឲ្យមានការស្តាប់សក្ខីកម្មប្រកបដោយប្រសិទ្ធភាព បើទោះជាផ្នែកមួយចំនួនខ្លះៗនៃការស្តាប់សក្ខីកម្មរបស់សាក្សី ត្រូវបានអូសបន្លាយបន្តិចបន្តួច ហើយបណ្តាលឲ្យលើសហួសពីពេលវេលាដែលបានកំណត់។

## ផ្នែកទី២ ៖ ការសង្ខេបសក្ខីកម្មរបស់សាក្សី

សាក្សី **ប៉ែជុយ ជីបសែ** គឺជាទាហានខ្មែរក្រហមម្នាក់ មុនពេលគាត់ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅមន្ទីរសន្តិសុខនៅឯខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ។ សាក្សីបានចូលខ្លួនផ្តល់សក្ខីកម្មកាលពីថ្ងៃចន្ទ និងថ្ងៃពុធ។ បន្ទាប់ពីការផ្តល់សក្ខីកម្មរបស់គាត់បានបញ្ចប់ហើយ ដើមបណ្តឹងរដ្ឋប្បវេណី គឺលោក **មាស សារ៉ាន់** ដែលជាវេជ្ជបណ្ឌិត និងជាជនរងគ្រោះម្នាក់នៃការជម្លៀសចេញពីរាជធានីភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានផ្តល់សក្ខីកម្មនៅអំឡុងវគ្គចុងក្រោយនៃសវនាការនៅថ្ងៃពុធ ហើយក៏បានបន្តការផ្តល់សក្ខីកម្មរបស់គាត់នៅសប្តាហ៍ក្រោយបន្តទៀត។

### ក. សក្ខីកម្មរបស់សាក្សី ប៉ែជុយ ជីបសែ

លោក **ប៉ែជុយ ជីបសែ** (TCW-507) បច្ចុប្បន្នជាគ្រូបង្រៀនមានវ័យ ៥៨ ឆ្នាំ មកពីខេត្ត សៀមរាប បានចូលមកផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការដោយមានមេធាវីប្រឹក្សាសាក្សីមួយរូបអមជាមួយផងដែរ គឺលោកមេធាវី **មឿន សុវណ្ណ**។[4] ក្នុងឆ្នាំ២០០៨ សាក្សីរូបនេះត្រូវបានបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេតសម្ភាសចំនួនពីរដង ហើយការសួរដេញដោលទៅលើរូបគាត់ចំពោះមុខអង្គជំនុំជម្រះសប្តាហ៍នេះ ភាគច្រើនផ្អែកទៅលើចម្លើយដែលសាក្សីបានរៀបរាប់កន្លងទៅ ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត និងបទសម្ភាសដែលសាក្សីបានធ្វើជាមួយ លោក **ហង់រី ឡូកា**។[5] សក្ខីកម្មរបស់សាក្សី គឺផ្តោតសំខាន់ទាក់ទងទៅនឹងប្រតិបត្តិការនៃមន្ទីរសន្តិសុខពង្រ[6] ដែលជាមណ្ឌលធ្វើការរបស់គាត់ក្នុងនាមជាស្មៀននៅចន្លោះឆ្នាំ១៩៧២ និងឆ្នាំ១៩៧៧។ សាក្សី **ប៉ែជុយ ជីបសែ** ក៏បានផ្តល់ផងដែរនូវព័ត៌មាននានាស្តីពី ការជម្លៀសចេញពីខេត្តសៀមរាប ការធ្វើទុក្ខបុកម្នេញលើមន្ត្រីរាជការរបស់រដ្ឋាភិបាល **លន់ នល់** ព្រមទាំងយោធា ក៏ដូចជាស្ថានភាពផ្សេងៗរបស់ជនភៀសខ្លួនពីទីក្រុង ឲ្យទៅរស់នៅក្នុងសហករណ៍។

#### *ក.១. ការជាប់ទាក់ទងជាមួយខ្មែរក្រហម*

សាក្សីបានក្លាយជាទាហានខ្មែរក្រហមម្នាក់នៅក្នុងឆ្នាំ១៩៧១ និងបានចូលរួមប្រយុទ្ធនៅក្នុងសមរភូមិជាហូរហែរហូតដល់ខ្មែរក្រហមបានរៀបចំនូវយុទ្ធនាការជួបជុំមួយនៅសាលមហោស្រព ចេនឡា ក្នុងឆ្នាំ១៩៧២

ហៅថា យុទ្ធនាការ ចេនឡាទី២។ នៅពេលដែលមេធាវីជាតិការពារក្តីលោក **នួន ជា** គឺមេធាវី **សុន អរុណ** ចោទសួរនូវព័ត៌មានលម្អិតពីការចូលរួមជាមួយខ្មែរក្រហម សាក្សី **ប៉េជុយ ជីបសែ** បានថ្លែងថា ការពិតទៅ លោកមិនមានបំណងចូលរួមទេ ប៉ុន្តែដោយសារគាត់ត្រូវបានខ្មែរក្រហមចាប់ខ្លួន និងនាំយកទៅភ្នំសន្ទុក ហើយក៏បានបញ្ចុះបញ្ចូលគាត់ឲ្យចូលរួមក្នុងចលនានេះ។ សាក្សីក៏បានទទួលស្គាល់ថា គាត់បានបោះបង់តួនាទីជាទ័ពខ្មែរក្រហមក្នុងអំឡុងពេលយុទ្ធនាការ ចេនឡាទី២ ហើយតពីនោះមក សាក្សីក៏បានវិលត្រឡប់ទៅស្រុកកំណើតរបស់គាត់វិញនៅឯស្រុកជីក្រែង ខេត្តសៀមរាប។ គាត់ក៏បានចាប់ផ្តើមធ្វើការនៅក្នុងមន្ទីរសន្តិសុខពង្រ។ ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់គាត់ សាក្សីបានយោងទៅលើសកម្មភាពមួយចំនួន ដែលគាត់បានធ្វើក្នុងនាមជាកងកម្លាំងយោធានៃមន្ទីរសន្តិសុខ។ សាក្សីបានរក្សាចម្លើយរបស់ខ្លួន ដែលបានឆ្លើយទៅកាន់ព្រះរាជអាជ្ញាអន្តរជាតិ លោក **ឌេល លីសាក់** ថា គាត់មានតួនាទីជាស្មៀននៃមន្ទីរសន្តិសុខចាប់តាំងពីឆ្នាំ១៩៧២ ដែលតួនាទីនេះតម្រូវឲ្យលោកជាអ្នករៀបចំឯកសារ និងរក្សាកំណត់ត្រានៃអ្នកទោស បូករួមទាំងជីវប្រវត្តិ ហើយនិងចម្លើយសារភាពរបស់អ្នកទោសទាំងនោះ។ បន្ទាប់ពីឆ្នាំ១៩៧៧ សាក្សីបានថ្លែងថា គាត់ត្រូវបានគេបញ្ជូនឲ្យត្រឡប់ទៅភូមិកំណើតរបស់គាត់វិញ ហើយបានធ្វើការនៅផ្នែកមួយនៃអង្គភាពចល័តនៅទីនោះ។

មេធាវីជាតិរបស់លោក **អៀង សារី** គឺលោក **អាង ឧត្តម** បានប្រឈមមុខជាមួយនឹងសាក្សី ដែលជាសាក្សីត្រៀមមួយរូប ដែលនឹងត្រូវចូលខ្លួនមកផ្តល់សក្ខីកម្មក្នុងពេលអនាគត[7] (មេធាវីមិនឲ្យសាក្សីអានឈ្មោះបុគ្គលម្នាក់លឺៗទេ ព្រោះត្រូវរក្សាការសម្ងាត់រហូតដល់ បុគ្គលរូបនេះ ត្រូវបានអង្គជំនុំជម្រះកោះហៅឲ្យមកផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការសាធារណៈ) ហើយដែលបុគ្គលរូបនេះត្រូវបានកំណត់អត្តសញ្ញាណដោយសាក្សី **ប៉េជុយ ជីបសែ** នៅក្នុងចម្លើយរបស់គាត់ជាមួយបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា ជាអតីតកម្មាភិបាលមួយរូបនៃមន្ទីរសន្តិសុខពង្រ។ សាក្សីបានមានប្រសាសន៍ថា ការយល់ច្រឡំនេះតែងតែកើតមានឡើងជាធម្មតា ព្រោះគាត់មានភាពជិតស្និទ្ធនឹង **តា គុណ** ដែលជាប្រធាននៃមន្ទីរសន្តិសុខនោះ ប៉ុន្តែធាតុពិត គាត់មាននាទីត្រឹមតែជាស្មៀនមួយរូបតែប៉ុណ្ណោះ។ លោក **ប៉េជុយ ជីបសែ** បានច្រានចោលនូវសក្ខីកម្មពីបុគ្គលរូបនេះ និងបានបញ្ជាក់ថា ត្រឹមប្រវត្តិគាត់ជាអ្នកមានទ្រព្យបន្តិចបន្តួចពីសង្គមចាស់ គាត់នឹងមិនអាចស្ថិតនៅក្នុងផ្នែកណាមួយនៃរចនាសម្ព័ន្ធខ្មែរក្រហមបានឡើយ។

### *ក.២. រចនាសម្ព័ន្ធរដ្ឋបាល និងទំនាក់ទំនងថ្នាក់តំបន់ ហើយនិងការបោសសម្អាតផ្ទៃក្នុង*

សាក្សីបានឲ្យដឹងថា ខ្មែរក្រហមបានបង្កើតឡើងនូវ "អង្គការសម្ងាត់" ដែលសមាសភាពមានពីសមាជិកសម្ព័ន្ធយុវជន និងសមាជិកបក្សកុម្មុយនីស្តកម្ពុជា ដោយឡែកលោកមិនមែនជាសមាជិកក្នុងអង្គការនេះ ហើយលោកក៏រឹតតែមិនបានដឹងច្បាស់ពីរបៀបដែលអង្គការនេះបំពេញមុខងារដូចម្តេចឡើយ។ ចំពោះរចនាសម្ព័ន្ធនៅមន្ទីរសន្តិសុខពង្រវិញ ត្រូវបានសាក្សីរៀបរាប់ថា **តា វ៉ន** ធ្លាប់ជាលេខាធិការនៅក្នុងមន្ទីរមួយនេះ តែក្រោយមកត្រូវបានជំនួសដោយ **តា គុណ**។ ក្នុងនាមជាលេខាធិការ គឺត្រូវរាយការណ៍ជូនទៅគណៈស្រុក ដែលដំបូងឡើយ គឺ

ដឹកនាំដោយ **តា សាន**។ ក្រោយមក **តា សុខ** បានបំពេញតួនាទីជំនួសឲ្យ **តា សាន** វិញ។ យោងតាមសាក្សីបានឲ្យដឹងថា **តា សុត** បានកាន់កាប់តួនាទីជាលេខាធិការតំបន់ ដែលហ៊ុមព័ទ្ធពីខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ។

**តា សាន** ត្រូវបានគេចោទប្រកាន់ថា ជាជនក្បត់ និងជំនួសដោយ **តា សុខ** មកពីខេត្តកំពត ជាខេត្តមួយដែលក្នុងអំឡុងសម័យខ្មែរក្រហម គឺត្រូវបានស្ថិតក្នុងផ្នែកមួយនៃភូមិភាគនិរតី។ ក្រោយមកទៀត **តា សុខ** បានចោទប្រកាន់ **តា វ៉ន** និងមនុស្សពាក់ព័ន្ធរបស់គាត់ថា ជាជនក្បត់ជាតិ និងបានដាក់ **តា គុណ** ឲ្យក្លាយជាលេខាធិការនៃមន្ទីរសន្តិសុខពង្រជំនួសវិញ។ នៅទីបំផុត **តា គុណ** និងអ្នកដទៃទៀតនៅក្នុងមន្ទីរនេះ ក៏ត្រូវបានចាប់ខ្លួនក្រោមការសង្ស័យថា មានជាប់ពាក់ព័ន្ធនឹងអំពើក្បត់ជាតិ ហើយក្រោយមកទៀត មន្ទីរសន្តិសុខពង្រត្រូវបានគេរុះរើចោលនៅក្នុងឆ្នាំ១៩៧៧។ សាក្សីដែលបានពិពណ៌នាអំពីស្ថានភាពនាពេលនោះដូចខាងក្រោមៈ

> *ការបិទមន្ទីរសន្តិសុខពង្រហ្នឹង ដោយសារវាចោទថា ពួកដែលធ្វើការនៅមន្ទីរសន្តិសុខ ហ្នឹង គឺជាពួកក្បត់ ដោយខ្មែរក្រហមគេចោទថាក្បត់។ ហើយក្បត់ហ្នឹងមិនមែនតែថា ពួកសន្តិសុខពង្រតែមួយទេ គឺថាក្បត់ទូទាំងប្រទេសតែម្តង គឺថាដូច្នេះពីតំបន់មួយទៅ តំបន់មួយ គឺខ្មែរក្រហមចោទគ្នាថាក្បត់មិនចេះចប់ ។*[8]

សាក្សីបានថ្លែងឲ្យដឹងថា ប្រធានមន្ទីរសន្តិសុខមានអំណាចធ្វើសេចក្តីសម្រេចក្នុងកម្រិតមួយ និងត្រូវរង់ចាំទទួលបទបញ្ជាពីលេខាធិការ ឬ គណៈស្រុកនៅលើបញ្ហានានាទាក់ទងនឹងការសម្រេចថា តើអ្នកទោសណាមួយគួរតែត្រូវយកទៅសម្លាប់។ ទោះជាយ៉ាងណា សាក្សីមិនដឹងថា តើអាជ្ញាធរថ្នាក់ស្រុក ក៏ត្រូវតែរង់ចាំទទួលបញ្ជាពីថ្នាក់ខ្ពស់ជាងនេះដែរឬយ៉ាងណានោះទេ?

សាក្សី **ប៉េជុយ ជីបសែ** អាចឆ្លុះបញ្ចាំងនូវដំណើរការពីការមានទំនាក់ទំនងគ្នានៅក្នុងលក្ខខណ្ឌនៃចម្លើយសារភាពរបស់អ្នកទោស ដោយសារក្នុងនាមជាស្មៀនមួយរូប ដែលលោកធ្លាប់បានចងក្រងចម្លើយសារភាពទាំងនោះទៅក្នុងបញ្ជីកំណត់ត្រាមួយ ហើយបញ្ជីនេះត្រូវបានដាក់ជូនទៅប្រធាននៃមន្ទីរសន្តិសុខ[9]។ ប្រធានមន្ទីរសន្តិសុខបញ្ជូននូវលទ្ធផល ឬ សកម្មភាពដែលចេញពីចម្លើយសារភាពទាំងនេះ ដាក់ជូនទៅប្រធានស្រុក[10] ដើម្បីធ្វើការកត់សម្គាល់ពីភាពធ្ងន់ធ្ងរនៃបទល្មើស និងធ្វើនូវសំណើទៅថ្នាក់ក្រោមវិញឲ្យប្រតិបត្តិនូវសកម្មភាពជាក់លាក់ផ្សេងៗ ឆ្លើយតបនឹងការរកឃើញនោះ។ ជម្រើសនានានៅក្នុងសំណើដែលស្នើបានឲ្យថ្នាក់ក្រោមប្រតិបត្តិតាម រួមមាន ស្នើឲ្យដោះលែង ស្នើឲ្យឃុំខ្លួន ឬ សម្លាប់។ សាក្សីក៏បានរម្លឹកផងដែរថា មានម្តងម្កាលដែល **តា សាន** នឹងមកកាន់មន្ទីរសន្តិសុខដើម្បីជួបជាមួយអ្នកជាប់ឃុំឃាំង។

ទាក់ទងនឹងការទទួលបានព័ត៌មានវិញ សាក្សីបានថ្លែងថា ខ្លួនបានចូលរួមក្នុងកិច្ចប្រជុំស្តីពី របៀបរបបធ្វើការងារ និងប្រជុំស្តីពីសេចក្តីកង្វល់មួយចំនួនចំពោះបញ្ហាអសន្តិសុខនៅក្នុងការិយាល័យរបស់គាត់ ប៉ុន្តែគាត់ស្នើរ

តែមិនដែលបានស្តាប់ ឬ ឮការផ្សព្វផ្សាយតាមវិទ្យុឡើយ។ ទោះជាយ៉ាងណាក្តី មេដឹកនាំមួយចំនួនរបស់គាត់ បានប្រាប់គាត់ថា **ប៉ុល ពត** គឺជាលេខាធិការរបស់បក្សកុម្មុយនីស្តកម្ពុជា និងថា លោក **ខៀវ សំផន** ជាប្រមុខរដ្ឋ។

### *គ.៣. ការជម្លៀស*

នៅពេលដែលស្រុកជីក្រែងបានធ្លាក់ក្នុងការកាន់កាប់ដោយខ្មែរក្រហមនៅឆ្នាំ១៩៧០ ប្រជាជនមួយចំនួននៅស្រុកកំពង់ក្តី ត្រូវបានជម្លៀសចេញ។ សាក្សីបានរៀបរាប់ថា ខ្លួនបានឃើញមានតែជនជាតិចិន មន្ត្រីរាជការ និងគ្រូបង្រៀន ប៉ុណ្ណោះ ដែលត្រូវបានគេបញ្ជូនឲ្យទៅនៅតាមភូមិមួយចំនួន ដែលមានចម្ងាយពី៣០ទៅ៤០ គីឡូម៉ែត្រ ពីផ្សារកំពង់ក្តី ប៉ុន្តែមិនបានដឹងថា ហេតុអ្វីបានជាក្រុមប្រជាជនទាំងនេះ គឺជាក្រុមគោលដៅនៃការជម្លៀសទេ។

សាក្សី **ប៉េជុយ ជីបសែ** មិនបានឃើញផ្ទាល់ភ្នែកនូវការជម្លៀសក្នុងឆ្នាំ១៩៧៥ នៅខេត្តសៀមរាបទេ ដោយសារពេលនោះ គាត់កំពុងធ្វើការនៅក្នុងមន្ទីរសន្តិសុខពង្រ។ ទោះជាយ៉ាងណា លោកបានឮតៗមកថា គ្រប់គ្នាត្រូវបានគេជម្លៀសចេញពីទីក្រុងកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ដោយធ្វើដំណើរថ្មើរជើង។ សាក្សីបានឮផងដែរថា ជនស៊ីវិលត្រូវបានគេបង្ខំឲ្យចាកចេញពីទីក្រុង និងត្រូវបានគំរាមកំហែងថា នឹងដាក់ទណ្ឌកម្ម និងរហូតដល់ការគំរាមសម្លាប់ផងដែរ។ ប្រជាជនទាំងប្រុសទាំងស្រី ទាំងក្មេងទាំងចាស់ បានស្លាប់បាត់បង់ជីវិតដោយសារតែការមានជម្ងឺផង ខ្វះស្បៀងអាហារផង និងគ្មានជំនួយគាំពារផ្នែកវេជ្ជសាស្ត្រណាមួយត្រូវបានផ្តល់ដល់អ្នកជម្លៀសទាំងនោះដែរ។ សាក្សី **ប៉េជុយ ជីបសែ** បានចាត់ទុកថា វាជាស្ថានភាពទុក្ខវេទនាដ៏លំបាកលំបិនរបស់ជនភៀសខ្លួនទាំងអស់ ពិសេសពួកគេត្រូវបានធ្វើដំណើរដ៏វែងឆ្ងាយដោយគ្មានការកំណត់ នៅទីតាំងពិតប្រាកដ ជាក់ស្តែងចំពោះអ្នកភៀសខ្លួនដែលបានមកពីទីក្រុងភ្នំពេញ។

### *គ.៤. សហករណ៍ និងការប្រព្រឹត្តិទៅលើប្រជាជន ១៧មេសា និងជនជាតិចាម*

សាក្សី **ប៉េជុយ ជីបសែ** បានរម្លឹកឡើងវិញជាបន្តទៀតថា នៅពេលស្រុកជីក្រែងបានធ្លាក់ទៅដៃរបស់ខ្មែរក្រហមក្នុងឆ្នាំ១៩៧០ ខ្មែរក្រហមបានលើកទឹកចិត្តបំផុសបំផុលប្រជាជនឲ្យតស៊ូប្រឆាំងនឹងរបប **លន់ នល់** ហើយដល់ចំណុចត្រង់នេះ ក្រុមគ្រួសារត្រូវបានចាប់ផ្តើមបំបែក៖ ក្មេងតូចៗបានទៅនៅក្នុងព្រៃដើម្បីចូលរួមជាមួយចលនាតស៊ូ ឬ ជ្រកកោនជាមួយខ្មែរក្រហម ស្របពេលដែលឪពុកម្តាយរបស់ពួកគេកំពុងបម្រើការងារនៅក្នុងសហករណ៍។ នៅពេលដែលប្រជាជនខេត្តសៀមរាប ត្រូវបានគេជម្លៀសចេញ ប្រជាជនស៊ីវិលទាំងនេះ ត្រូវបានគេផ្លាស់ប្តូរឲ្យទៅរស់នៅតាមភូមិចុងកាត់មាត់ញកនានា។ សាក្សីមិនដឹងថា តើមានមនុស្សប៉ុន្មាននាក់ដែលត្រូវបានជម្លៀសនាពេលនោះទេ ប៉ុន្តែបានអះអាងថា មិនមែនគ្រប់ជនភៀសខ្លួនទាំងអស់ដែលបានមកតាំងលំនៅថ្មីនៅស្រុកជីក្រែង សុទ្ធតែជាអ្នកមកពីខេត្តសៀមរាបឡើយ។

ក្រោយពេលមកដល់សហករណ៍មួយចំនួន ប្រធានសហករណ៍បានចាប់ផ្តើមបំបែកប្រជាជនភៀសខ្លួនឲ្យទទួលខុសត្រូវការងារផ្សេងៗគ្នា រស់នៅក្នុងទីតាំងខុសៗគ្នា ហើយដែលសមាជិកគ្រួសារទៀតសោត ក៏ត្រូវបានបំបែកចេញពីគ្នាផងដែរ។ ជនភៀសខ្លួនទាំងអស់ត្រូវបានគេយល់ឃើញថា ជាប្រជាជនថ្មី ឬ ប្រជាជន១៧មេសា ដែលជាក្រុមមនុស្សដែលសាក្សីបានថ្លែងថា មានស្ថានភាពរស់នៅក្នុងភាពភ័យខ្លាចជាប្រចាំ។ ពួកគេត្រូវបានចាត់ទុកជាក្រុមមនុស្ស ឬ ជាអ្នកមានវណ្ណៈមួយផ្សេង និងត្រូវបានចោទប្រកាន់ថា ជាក្រុមមនុស្សដែលមានការជាប់ពាក់ព័ន្ធជាមួយនឹង ពួកចក្រពត្តិនិយមអាមេរិកាំង ហើយពួកគេ ក៏ជាប្រភេទក្រុមមនុស្សដែលត្រូវបានគេឈ្លបមើល និងតម្រូវឲ្យធ្វើ ការលំបាកៗដើម្បីលត់ដំខ្លួន។ ខណៈពេលដែលការបរិភោគអាហាររួម ត្រូវបានអនុវត្តរួចទៅហើយ មុនពេលការមកដល់របស់ជនភៀសខ្លួន ក្នុងនោះដែលប្រជាជនចាស់ ឬ ប្រជាជនមូលដ្ឋាន មិនទាន់រៀបរយ (ងាយស្រួល) នឹងទទួលនូវសមាជិកថ្មីដែលជាជនភៀសខ្លួនទាំងនេះឡើយ ហើយការពិត ខ្មែរក្រហមបានលើកទឹកចិត្តអ្នកស្រុកដែលជាប្រជាជនមូលដ្ឋានទាំងនោះ ឲ្យទុកប្រជាជនថ្មីថា ជាអ្នកដែលបានរស់នៅក្នុងរដ្ឋបាលរបស់របប **លន់ នល់**។

ប្រជាជន ១៧មេសា ត្រូវតែលាក់បាំងនូវប្រវត្តិពិតប្រាកដរបស់ពួកគេ (បើគេជាអតីតមន្ត្រី រដ្ឋការ ឬ ពាក់ព័ន្ធនឹងរបប **លន់ នល់**) ហើយចំពោះអ្នកដែលត្រូវបានគេរកឃើញថាមានទំនាក់ទំនងនឹងរបបនេះ នឹងត្រូវបានគេយកទៅសម្លាប់។ ប្រជាជនចាស់មាននាទីឈ្លបតាមដាននូវរាល់ សកម្មភាពរបស់ប្រជាជនថ្មី ហើយជាញឹកញាប់ត្រូវបានគេចោទប្រកាន់ថា បានលួច បានប្រព្រឹត្តទង្វើអសីលធម៌ និងជាមនុស្សខ្ជិលច្រអូស។ បើទោះជាយ៉ាងណា ប្រជាជនចាស់មួយចំនួន ត្រូវបានចាប់ខ្លួនក្រោមការប្រព្រឹត្តិនូវកំហុសដូចគ្នានេះផងដែរ។ ការផ្តន្ទាទោសរវាងប្រជាជនចាស់ និងប្រជាជនថ្មី គឺមិនដូចគ្នាឡើយ (សូមមើលផ្នែកខាងក្រោម ស្តីពីមន្ទីរសន្តិសុខពង្រ)។

បន្ទាប់ពីឆ្នាំ១៩៧៥ មានជនជាតិចាមខ្លះ ត្រូវបានជម្លៀសទៅដល់ភូមិកំណើតរបស់សាក្សី ផ្ទាល់។ ពួកគេទាំងនេះត្រូវបានដាក់ឲ្យរស់នៅតាមផ្ទះអ្នកស្រុក និងត្រូបានបង្ខំឲ្យបរិភោគសាច់ជ្រូក ដែលនៅក្នុងសាសនាអ៊ីស្លាម វាជាប្រភេទសាច់ត្រូវបានហាមឃាត់។ ដូចជាប្រជាជនថ្មីដទៃទៀតដែរ ពួកគេត្រូវបានបង្ខំឲ្យធ្វើការធ្ងន់ៗរួមមាន ជីកប្រឡាយ ឬ ជីកទំនប់ទឹកជាដើម។ ការរើសអើងប្រឆាំងនឹងក្រុមគោលដៅជាក់លាក់ទាំងនេះ នៅតែបន្តកើតមានឡើងសូម្បីនៅក្រោយឆ្នាំ ១៩៧៧ ហើយក្តីក៏ដោយ។ សាក្សី **ប៉េជុយ ជីបសែ** បានឃើញដោយផ្ទាល់ភ្នែក បន្ទាប់ពីគាត់បានវិលត្រឡប់ទៅដល់ភូមិឋានរបស់គាត់វិញ ខណៈដែលមន្ទីរសន្តិសុខពង្រត្រូវបានបិទ។

លើសពីនេះទៀត ក្នុងពេល **តា សុខ** នៅជាប្រធានស្រុក ប្រជាជន១៧មេសា ត្រូវបានគេចោទប្រកាន់ថា បានបង្កការបះបោរប្រឆាំងនឹងខ្មែរក្រហម និងត្រូវបានគេយកសម្លាប់នៅកំពង់ក្តី។ សាក្សីបានពិពណ៌នាអំពីរបៀបដែលប្រជាជនថ្មី ត្រូវបានគេចោទថាបានសម្លាប់ទាហានខ្មែរក្រហម តាមរយៈការប្រើល្បិច (នយោបាយ) ដើម្បីចាប់អ្នកទាំងនោះ ដោយហៅពួកគេថាឲ្យទៅចូលរួមកិច្ចប្រជុំជាមួយ "បងប្អូនណាដែលមានថ្នាក់ មានកាំបិត ពូថៅ

នៅហ្នឹងដៃ គឺបងប្អូនមកជួបជុំគ្នាចុះ" ហើយដល់ពេលមកដល់កន្លែងប្រជុំ ខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនទាំងនោះទុកដាក់កាំបិត ពូថៅ នៅមួយកន្លែង។ បន្ទាប់មក ពួកគេទាំងនេះ ក៏ត្រូវបានចាប់ខ្លួនពីបទរំលោភលើច្បាប់ដោយការប្រើអាវុធប្រឆាំងនឹងខ្មែរក្រហម។ ហើយចុងក្រោយពួកគេ ត្រូវបានគេចង និងរុញបញ្ចូលក្នុងឡាន ហើយក៏ត្រូវបាននាំយកទៅកន្លែងសន្តិសុខផ្សេងពីមន្ទីរសន្តិសុខពង្រ។

### *ក.៥. មន្ទីរសន្តិសុខពង្រ*

សាក្សី **ប៉ែជុយ ជីបសែ** បានដឹងរឿងរ៉ាវមួយចំនួនពីមេដឹកនាំរបស់លោក ដែលមន្ទីរសន្តិសុខចាប់ពីឆ្នាំ ១៩៧២-១៩៧៧ គឺជាកន្លែងធ្វើការអប់រំកែប្រែ និងកសាងខ្លួនរបស់អ្នកទោសដើម្បីឲ្យក្លាយជាមនុស្សល្អ។ ទោះជាយ៉ាងណាក្តី លោកបានរម្លឹកឡើងវិញថា មួយចំនួននៃអ្នកទោសទាំងនោះ ចុងក្រោយត្រូវបានគេយកទៅសម្លាប់។ ដូច្នេះ សាក្សីជឿជាក់ថា "ការនិយាយ របស់វាគឺមិនពិត...ល្អតែមាត់ តែចិត្តគំនិតវាអាក្រក់" ។[11]

សាក្សីបានឲ្យដឹងថា អ្នកទោសនៅមន្ទីរសន្តិសុខពង្រ គឺជាប្រជាជនស៊ីវិលទាំងអស់ តែត្រូវបានលាបពណ៌ដោយប្រធានគ្រប់គ្រងផ្ទាល់មួយចំនួនរបស់លោក ថាអ្នកទោសទាំងនោះជាពួក ចក្រពត្តិនិយម និងមូលធននិយម។ សាក្សីបានថ្លែងនៅក្នុងសក្ខីកម្មរបស់គាត់ថា ក្នុងនាមគាត់ជាបុគ្គលិកនៃមន្ទីរសន្តិសុខពង្រ ពេលខ្លះមេកើយរបស់គាត់បានស្នើឲ្យគាត់ទៅផ្សារកំពង់ក្តី ដើម្បីស្វែងរក និងចាប់ខ្លួនមនុស្ស ដែលបានប្រព្រឹត្តបទល្មើសផ្សេងៗ ដូចជាចោរលួច អ្នកខិលច្រអូស ឬ អ្នកខុសសីលធម៌ជាដើម ហើយបើតាមសាក្សីបានឲ្យដឹងថា អ្នកខុសសីលធម៌មានច្រើនប្រភេទ មិនថាជារឿងប្តីគេ ឬ ប្រពន្ធគេ ឬ ក៏ជាទំនាក់ទំនងស្នេហារវាងប្រជាជនថ្មី និងប្រជាជនចាស់ទេ ប៉ុន្តែ ភាគច្រើនជានារីតែម្តង។ ក្នុងឆ្នាំ ១៩៧៤ រាល់អ្នកទាំងឡាយណាដែលត្រូវបានគណៈស្រុក ចោទថាជា "ចោរព្រៃ" (មានទាំងកុមារ និងមនុស្សចាស់) អ្នកទាំងនេះនឹងត្រូវបានគេចាប់ខ្លួន យកទៅដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខ។ យោងតាមសាក្សីបានឲ្យដឹងថា "ចោរព្រៃ" ទាំងនេះ គឺសំដៅទៅលើអ្នកទាំងឡាយណា ដែលតស៊ូរើបម្រះប្រឆាំងជាមួយខ្មែរក្រហម ហើយរត់ចូលព្រៃ តែដល់ក្រោយមក ក្រុមនេះមានទំនាក់ទំនងជាមួយខាង **លន់ នល់**។ ពួកគេទាក់ទងគ្នាទៅវិញទៅមក ហើយខាង **លន់ នល់** បានផ្តល់ឧទ្ធម្ភាគចក្រមកដឹកអ្នកទាំងនោះពីក្នុងព្រៃទៅ តួយ៉ាងដូចមាន កើតឡើងនៅក្នុងខេត្តសៀមរាប។ ក្រុមមនុស្សទាំងនេះត្រូវបានខាង **លន់ នល់** យកទៅបំពាក់បំប៉ន រួចបានបញ្ជូនមកដាក់នៅកន្លែងចាស់ក្នុងព្រៃវិញ ដូច្នេះហើយ បានជាខ្មែរក្រហមចោទក្រុមនេះថា ជាចោរព្រៃ ព្រោះបានចូលដៃជើងជាមួយ **លន់ នល់**។

ប្រធានភូមិទាំងឡាយ ក៏ត្រូវបានប្រគល់អ្នកទោស បូករួមជាមួយនឹងព័ត៌មានផ្សេងៗដែលទទួលបានពីការចាប់ខ្លួនអ្នកទាំងនេះជូនទៅដល់ថ្នាក់លើរបស់ខ្លួន។ សាក្សីត្រូវបានគេបញ្ជាឲ្យធ្វើកំណត់ កត់សម្គាល់ថាតើអ្នកទោសជាប្រជាជនថ្មី ឬ ប្រជាជនចាស់ ហើយប្រសិនបើអ្នកទោសស្ថិតក្នុងផ្នែកនៃប្រជាជនថ្មី គេនឹងដាក់ឲ្យនៅក្នុងកន្លែងខុសគ្នាពីប្រជាជនចាស់ ឬ ក៏ប្រសិនបើអ្នកទោសទាំងពីរប្រភេទនេះ ត្រូវតែដាក់ឃុំខ្លួនក្នុងកន្លែងតែមួយ

ប្រជាជនថ្មីតម្រូវឲ្យស្ថិតនៅក្នុងកន្លែងមួយដែលទាបជាងប្រជាជនចាស់។ ដោយឡែកចំពោះការដាក់ទណ្ឌកម្ម ដែលកើតចេញបទល្មើសដូចគ្នាវិញ ប្រជាជនថ្មីនឹងត្រូវទទួលរងធ្ងន់ធ្ងរជាងប្រជាជនចាស់។

មានតែអ្នកជាប់ឃុំជាស្ត្រីទេ ដែលត្រូវបានអនុញ្ញាតឲ្យចេញទៅក្រៅ និងធ្វើការងារផ្សេងៗបាន។ អ្នកទោសមួយចំនួន ត្រូវបានគេធ្វើទារុណកម្មក្នុងពេលសួរចម្លើយ បើពួកគេបដិសេធមិនឆ្លើយសំណួរ ឬ សារភាពទោសកំហុសទេ។ ការធ្វើទារុណកម្ម រួមបញ្ចូលទាំងការវាយនឹងខ្សែតី ថ្មោង រំពាត់ ឬ ដំបង។ អ្នកទោសមួយចំនួនទៀត ត្រូវបានសម្លាប់ និង យកទៅកប់ឆ្ងាយពីមន្ទីរសន្តិសុខ។ អ្នកជាប់ឃុំឃាំងមួយចំនួនបានស្លាប់ ដោយសារតែមិនបានទទួលរបបអាហារគ្រប់គ្រាន់ ពោលគឺ មានត្រឹមតែទឹកបបររាវៗ ហើយនិងអាចបណ្តាលមកពិលក្ខខណ្ឌអាកាសធាតុក្នុងរដូវត្រជាក់ផងដែរ។

### *ក.៦. ការប្រព្រឹត្តិទៅលើទាហាន និងមន្ត្រីរដ្ឋការ លន់ នល់*

សាក្សី **ប៉េជុយ ជីបសែ** បានថ្លែងថា មុនឆ្នាំ១៩៧៥ ទាហាន **លន់ នល់** ដែលគេចាប់បាន ត្រូវគេយកទៅសម្លាប់ភ្លាមៗ។ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មក ក្នុងអំឡុងពេលជម្លៀស ប្រជាជននៅខេត្តសៀមរាប អតីតទាហាន និងមន្ត្រីរដ្ឋការក្នុងរបប **លន់ នល់** និងក្រុមគ្រួសាររបស់ពួកគេ ត្រូវបានយកទៅទុកនៅតាមអាគារចាស់ៗមួយចំនួនក្បែរផ្សារកំពង់ក្តី។ ដូចគ្នានឹងមន្ទីរសន្តិសុខពង្រផងដែរ ផ្សារកំពង់ក្តី មានទីតាំងស្ថិតនៅស្រុកជីក្រែង ចម្ងាយឆ្ងាយពីគ្នាប្រមាណជា៧ គីឡូម៉ែត្រ។ យោងតាមសាក្សីបានឲ្យដឹងថា អតីតទាហាន មន្ត្រីរដ្ឋការក្នុងរបប **លន់ នល់** ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ ត្រូវបានគេឃុំខ្លួនទុកសួរចម្លើយ ធ្វើទារុណកម្ម និងក្រោយមកត្រូវបានយកទៅសម្លាប់។[12] ទោះជាយ៉ាងណាក្តី សាក្សីបានដឹងឮព័ត៌មាននេះតៗពីគេតែប៉ុណ្ណោះ។ គាត់បានដឹងនៅព័ត៌មាននេះ ពីមនុស្សផ្សេងទៀត។ លោក **ប៉េជុយ ជីបសែ** បានបញ្ជាក់ថា សេចក្តីថ្លែងការណ៍របស់លោកនៅក្នុងបទសម្ភាសន៍ជាមួយបុគ្គលិកមកពីការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រង់ចំណុចដែលគាត់និយាយថា អតីតមន្ត្រីរដ្ឋការ **លន់ នល់** ទាំងនេះ រួមជាមួយនឹងក្រុមគ្រួសាររបស់ពួកគេ ត្រូវបានខ្មែរក្រហមដឹកជញ្ជូនតាមឡានក្រោមមកដឹងថា ពួកគេនឹងត្រូវយកទៅចូលរួមវគ្គសិក្សារៀនសូត្រនោះ។ ការពិត ពួកគេទាំងនោះ គឺត្រូវបានយកទៅសម្លាប់នៅភូមិម្កាក់ទៅវិញទេ ដែលភូមិនេះមានទីតាំងប្រមាណជា ១០ គីឡូម៉ែត្រ ឆ្ងាយពីមន្ទីរសន្តិសុខ។ សាក្សី បានអះអាងថា គាត់មិនបានដឹងថា តើអង្គភាពខ្មែរក្រហមណាមួយ ដែលទទួលបន្ទុកចាំយាម និងសម្លាប់អ្នកទោសទាំងនោះឡើយ។ ទោះជាយ៉ាងណាក្តី សាក្សីបានបញ្ជាក់ថា ការសម្លាប់ ត្រូវបានរៀបចំឡើងដោយមនុស្សមកពីថ្នាក់តំបន់ និងមិនមែនធ្វើដោយកងកម្លាំងក្នុងមូលដ្ឋានទេ។ សាក្សីបានឲ្យដឹងថា ខ្លួនបានទទួលព័ត៌មាននេះពីកម្មាភិបាលដែលទទួលខុសត្រូវក្នុងការសម្លាប់ បន្ទាប់ពីត្រឡប់ពីភូមិម្កាក់វិញ។ សាក្សី **ប៉េជុយ ជីបសែ** បានបដិសេធថា កងកម្លាំងសន្តិសុខ មកពីមន្ទីរសន្តិសុខពង្រ មិនមានតួនាទីពាក់ព័ន្ធណាមួយនៅក្នុងការសម្លាប់នេះឡើយ។ សាក្សីក៏បានថ្លែងផងដែរថា លោកបានឮអំពីបែបបទនៃការសម្លាប់ក្រុមមនុស្សទាំងនេះ ដោយគ្រប់គ្នា រួមទាំងកុមារ ត្រូវបានគេបិទមុខនឹងក្រណាត់ បន្ទាប់មកសម្លាប់។ ក្នុងចំណោមអ្នកទាំងនោះ មានមនុស្សបីនាក់ ដែលធ្លាប់រស់នៅក្នុងភូមិរបស់គាត់។

### ក.៧. អត្តចរិត និងភាពជឿជាក់បាននៃសាក្សី

សក្ខីកម្មរបស់សាក្សី ជាទូទៅមានលក្ខណៈស៊ីចង្វាក់គ្នារវាងសក្ខីកម្មនៅក្នុងបន្ទប់សវនាការ និងសក្ខីកម្មដែលគាត់បានផ្តល់ ឲ្យបុគ្គលិកការិយាល័យសហចៅក្រមស៊ើបអង្កេត ព្រមទាំងបទសម្ភាសន៍ជាមួយនឹងលោក **ហង់រី ឡូកា** ផងដែរ ជាពិសេស ព័ត៌មានទាក់ទងនឹងការជម្លៀស រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋាន និងលំដាប់លំដោយនៃព្រឹត្តិការណ៍មួយចំនួន។ ទោះជាយ៉ាងណា សាក្សីហាក់ដូចជាមិនបាននៅជិតដល់ ឬ មិនបានឃើញផ្ទាល់ភ្នែកឡើយនូវព្រឹត្តិការណ៍មួយចំនួនដែលបានពិពណ៌នាកន្លងទៅ នៅក្នុងសម្ភាសន៍មុនៗរបស់គាត់នោះទេ ជាពិសេស ហេតុការណ៍ទាក់ទងទៅនឹងការសម្លាប់មនុស្ស។ នៅពេលដែលគាត់ត្រូវបានប្រឈម សុំឲ្យធ្វើការពិពណ៌នាពីភាពរន្ធត់តក់ស្លុតនៃការប្រហារជីវិតអ្នកណាម្នាក់ សាក្សីនិយាយថា លោកគ្រាន់តែបានឮព័ត៌មាននេះពីប្រភពផ្សេងទៀតតែប៉ុណ្ណោះ។ មានពេលមួយនោះ មេធាវីជាតិការពារក្តី លោក **នួន ជា** គឺលោក **សុន អរុណ** បានតតាំងសាក្សីទៅនឹងការពិពណ៌នាមួយ ដែលដកស្រង់ចេញពីក្នុងបទសម្ភាសន៍ ដែលសាក្សីបានធ្វើជាមួយលោក **ហង់រី ឡូកា**។ ឃ្លាមួយនៃបទសម្ភាសន៍ គឺសាក្សីបានទទួលស្គាល់ថា គាត់បានសម្លាប់អ្នកទោសចំនួនពីរនាក់។ សាក្សី **ប៉េជុយ ជីបសែ** បានថ្លែងថា លោកគ្រាន់តែធ្លាប់បានវាយអ្នកទោសមួយចំនួន តែត្រង់ថាបានវាយជាក់លាក់ប៉ុន្មាននាក់ឲ្យច្បាស់លាស់ គឺលោកមិនអាចចាំបានទេ ហើយថា លោកធ្វើដូច្នោះ ក៏ព្រោះតែខ្មែរក្រហមមិនជឿជាក់លើគាត់តែប៉ណ្ណោះ។ ជាការពិតណាស់ សក្ខីកម្មរបស់គាត់ទាំងអស់ បានបង្ហាញឲ្យឃើញថា ភាគច្រើននៃចម្លើយដែលបានផ្តល់នៅក្នុងបទសម្ភាសន៍ជាមួយលោក **ហង់រី ឡូកា** និងបុគ្គលិកមកពីខាងការិយាល័យចៅក្រមស៊ើបអង្កេត គឺជាព័ត៌មានដឹងឮដោយប្រយោល ឬ តាមពាក្យចចាមអារ៉ាមតែប៉ុណ្ណោះ រួមបញ្ចូលទាំងព័ត៌មានពាក់ព័ន្ធនឹងការជម្លៀសក្នុងក្រុងសៀមរាប ត្រូវបានគេប្រព្រឹត្តទៅយ៉ាងណានោះក៏ដោយ។

## ខ. សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់

បន្ទាប់ពីសក្ខីកម្មរបស់សាក្សី **ប៉េជុយ ជីបសែ** បានបញ្ចប់ទៅ អង្គជំនុំជម្រះសាលាដំបូង បានកោះហៅដើមបណ្តឹងរដ្ឋប្បវេណី **មាស សារ៉ាន់** (TCCP-82) ឲ្យចូលខ្លួនមកផ្តល់សក្ខីកម្ម។ ដើមបណ្តឹងរដ្ឋប្បវេណីកើតនៅថ្ងៃទី ១២ ខែឧសភា ឆ្នាំ១៩៤៩ ក្នុងខេត្តស្វាយរៀង។ បច្ចុប្បន្ន គឺជាពោះម៉ាយកូនមួយ រស់នៅក្នុងទីក្រុងភ្នំពេញ និងមានអាជីពការងារផ្នែកវេជ្ជសាស្ត្រ។ មេធាវីតំណាងរដ្ឋប្បវេណី **គ្រីស្ទីន ម៉ាទីណូ** បានសួរសំណួរទៅកាន់ដើមបណ្តឹងរូបនេះនៅវគ្គចុងក្រោយនៃសវនាការនៅថ្ងៃពុធ ហើយសក្ខីកម្មរបស់គាត់ នឹងត្រូវលើកទៅស្តាប់ជាបន្តនៅថ្ងៃព្រហស្បតិ៍ ទី២២ ខែវិច្ឆិកា ឆ្នាំ២០១២។

### ខ.១. ប្រវត្តិវិជ្ជាជីវៈមុនរបបកម្ពុជាប្រជាធិបតេយ្យ

លោក **មាស សារ៉ាន់** បានចូលសិក្សានៅសាលាពេទ្យពីឆ្នាំ១៩៦៩ ដល់ឆ្នាំ ១៩៧២។ បន្ទាប់មក គាត់បានធ្វើការនៅក្នុងផ្នែកជម្ងឺរបេងនៅមន្ទីរពេទ្យព្រះកេតុមាលា ដែលជាមន្ទីរពេទ្យធំជាងគេទីពីរនៅក្នុងរាជធានីភ្នំពេញ។

ក្នុងឆ្នាំ១៩៧៣ លោកបានចាកចេញពីមន្ទីរពេទ្យ ហើយក៏បានក្លាយជាទាហានដើម្បីបំពេញកាតព្វកិច្ចយោធា។ លោក **មាស សារ៉ាន់** បានឲ្យដឹងថា កាលជំនាន់នោះ មន្ត្រីរដ្ឋការនៃស្ថាប័ននានា គឺថា "រដ្ឋតម្រូវឲ្យទៅបំពេញកិច្ចជាទាហាន១៨ខែ"។ ក្នុងពេលកំពុងដំណើរការជ្រើសរើសប៉ុស្តិ៍ហ្វឹកហ្វឺនទាហាន គាត់បានជ្រើសរើសយកមណ្ឌលមួយ ដែលជាកន្លែងមិនទាន់មានចម្បាំងធ្ងន់ធ្ងរ ហើយនៅទីនោះផងដែរ លោក **មាស សារ៉ាន់** បានរៀបការជាមួយប្រពន្ធរបស់គាត់។ នៅក្នុងមជ្ឈមណ្ឌលហ្វឹកហ្វឺនទ័ពថ្មើរជើងលេខ៤ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានព្យាបាលជម្ងឺដល់ទាហានដែលទើបនឹងជ្រើសបានថ្មីៗជាច្រើននាក់ បើទោះបីជា មានការខ្វះខាតថ្នាំសង្កូវក្នុងការព្យាបាលជាប្រក្រតីក៏ដោយ។ នៅចុងឆ្នាំ១៩៧៤ លោក **មាសសារ៉ាន់** អមដោយភរិយាមានផ្ទៃពោះប្រាំបីខែរបស់គាត់ ត្រូវបានគេកោះហៅឲ្យត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញ។

## *ខ.២. ស្ថានភាពនៅទីក្រុងភ្នំពេញមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥*

ពេលមកដល់រាជធានីភ្នំពេញ លោក **មាស សារ៉ាន់** ត្រូវបានស្នើឲ្យមកជួបជុំធ្វើការជាមួយបុគ្គលិកពេទ្យផ្សេងទៀតនៅបុរីកីឡា ដែលលោកបានពិពណ៌នាថា មិនមែនមន្ទីរពេទ្យពេញលក្ខណៈត្រឹមត្រូវនោះទេ ប៉ុន្តែវាជាមជ្ឈមណ្ឌលសង្គ្រោះបន្ទាន់មួយ មានកន្លែងវះកាត់ពីរកន្លែង។ លោកបានរៀបរាប់បន្តទៀតថា មន្ទីរពេទ្យមួយនេះប្រៀបដូចជាមណ្ឌលវះកាត់ច្រើនជាង និងមានមុខងារទទួលព្យាបាលជនរងគ្រោះពីការបាញ់ផ្លោងរបស់ខ្មែរក្រហមចូលក្នុងទីក្រុងភ្នំពេញ។

បើយោងតាម លោក **មាស សារ៉ាន់** បានឲ្យដឹងថា បុរីកីឡាទាំងមូល ក៏ដូចជាកន្លែងវះកាត់ នេះ ស្ថិតក្រោមការត្រួតត្រារបស់លោកឧត្តមសេនីយ៍ **អ៊ុង សុងសឿន**។ នៅពេលនោះ បុគ្គលិកពេទ្យ ជាច្រើនបានមកដល់បុរីកីឡា ដោយសារតែមានការអំពាវនាវពីរដ្ឋាភិបាលទៅកាន់សាលាពេទ្យទាំងអស់របស់រដ្ឋ ឲ្យបញ្ជូនសិស្សពេទ្យមកជួយបម្រើការងារផ្នែកវេជ្ជសាស្ត្រ។

នៅប៉ុន្មានថ្ងៃមុនពេលរាជធានីភ្នំពេញ ត្រូវបានកាន់កាប់ដោយខ្មែរក្រហម ស្ថានភាពជាទូទៅ នៅក្នុងរាជធានីភ្នំពេញ គឺនាំឲ្យលោក **មាស សារ៉ាន់** ក៏ដូចជាប្រជាជនដទៃទៀតមានការ "ភ័យជាប់ ជាប្រចាំ" ដោយសារការបន្តបាញ់ផ្លោងឥតឈប់ឈរខិតជិតចូលដល់ក្នុងទីក្រុង និងការបាញ់ឆ្មក់ តទល់ទៅវិញពីកងទ័ព **លន់ នល់**។ ជាលទ្ធផលនៃការច្បាំងគ្នានេះ បាននាំឲ្យមនុស្សម្នាភ័យ និងបានរត់មកពីតំបន់ខាងក្រៅៗ ចូលមកយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងទីក្រុង។ ដើមបណ្តឹងរដ្ឋប្បវេណី បានពណ៌នាស្ថានភាពគ្រានោះថា គ្រប់គ្នាភ័យស្លន់ស្លោ និងមានសភាពវឹកវរ ប៉ុន្តែក៏មានមនុស្សមួយចំនួនសប្បាយរីករាយ ព្រោះយល់ថាជ័យជម្នះរបស់ខ្មែរក្រហម នឹងនាំមកនូវសន្តិភាពដល់ប្រទេសជាតិ "ប្រហែលជាចប់សង្គ្រាមក្នុងពេលឆាប់ៗហ្នឹងហើយ និងលែងមានចម្បាំង ហើយក៏លែងមានការទម្លាក់គ្រាប់បែក" ទៀតដែរ។

ក្នុងយប់ថ្ងៃទី១៦ មុនពេលការដួលរលំនៃទីក្រុងភ្នំពេញ មានរថយន្តសង្គ្រោះបន្ទាន់(អំប៊ូលឡង់) យ៉ាងច្រើនបាននាំយកអ្នករងរបួសពីការទម្លាក់គ្រាប់បែក និងការបាញ់គ្នាដឹកឆ្ពោះទៅកាន់មន្ទីរពេទ្យបុរីកីឡា។ ការប្រយុទ្ធគ្នាយ៉ាងខ្លាំងរវាងគូបដិបក្ខទាំងពីរ បានឮកក្រើកខ្លាំងនៅម្តុំស្ពានជ្រោយចង្វារ ធ្វើឲ្យលោក **មាស សារ៉ាន់** ឡើងទៅលើផុតនៃអគារ សម្លឹងមើលទៅម្តុំនោះ ហើយក៏ឃើញភ្លើងឆេះយ៉ាងសន្ធោសន្ធៅនៅបរិវេណជុំវិញទីនោះ។ ខណៈពេលដែលមនុស្សមួយចំនួនបានសម្រេចចិត្ត ចាកចេញពីមណ្ឌលនេះដោយសារតែការភ័យខ្លាច លោកផ្ទាល់បានសម្រេចចិត្តបន្តនៅព្យាបាលយូរជាងគេ ទោះបីជាគាត់បានចប់ពីវេនហើយក៏ដោយ ហើយខណៈដែលអ្នកបន្តវេនពីលោកមិនទាន់មកដល់។

### *ខ.៣. ការមកដល់នៃទាហានខ្មែរក្រហម*

នៅពេលព្រឹកថ្ងៃទី ១៧ ខែមេសា នៅប្រមាណជាវេលាម៉ោង ៨ព្រឹក លោក **មាស សារ៉ាន់** បានឮតែស្នូរកាំភ្លើងមកពីគ្រប់ជ្រុងនៃទីក្រុង “គឺថាមានការបាញ់កាំភ្លើងផាំងៗៗៗ ម្តងនៅជ្រុងខាងនេះ ម្តងនៅខាងនោះ។ មិនមែនជាកាំភ្លើងបាញ់តតាំងគ្នាទេ” ហើយដើមបណ្តឹងរដ្ឋប្បវេណីក៏បានឃើញ ទាហានខ្មែរក្រហមរុលឆ្ពោះមកកាន់ទីក្រុងពីទិសខាងលិច។ គាត់បានផ្តល់សក្ខីកម្មថា មានរថក្រោះមួយចំនួនដោយមានទាហានអង្គុយនៅពីលើ។ ទាហានទាំងនោះស្ថិតនៅក្នុងសម្លៀកបំពាក់ ពណ៌ខ្មៅ ជាមួយស្បែកជើងខ្មៅ និងមួករបៀបម៉ៅនិយម ហើយមានមួយចំនួនទៀត មានស្លៀកតែខោ តែមិនពាក់អាវទេ។ ពួកគេបានកាន់កាំភ្លើងចង្អុលទិសទៅលើមេឃ ហើយក៏បានឆ្លងកាត់បុរីកីឡាដោយឆ្ពោះទៅទិសខាងកើត។ ដើមបណ្តឹងរដ្ឋប្បវេណីបានដើរតាមទាហានខ្មែរក្រហមម្នាក់ ដើម្បីសួរនាំគេក្រែងបានព័ត៌មាន ឬ ផែនការថ្មីអ្វីខ្លះ ដែលអាចនឹងកើតឡើងបន្តទៀត និងបានចូលទៅតាមមើលនៅពេលទាហានរូបនោះចូលទៅក្នុងផ្ទះមួយប្រមាណជាកន្លះម៉ោង ហើយក្រោយមក ក៏បានចេញមកក្រៅវិញ តែមិនមានឱកាសនិយាយជាមួយខ្មែរក្រហមរូបនោះទេ ព្រោះគេដូចជាប្រញាប់ប្រញាល់ពេក។ បន្ទាប់ពីនោះមក លោក **មាស សារ៉ាន់** បានឃើញស្ត្រីវ័យជំទង់ពីរនាក់ដែលមានអាយុប្រហែល១៨ ឬ ១៩ ឆ្នាំ វេចខ្ចប់ឥវ៉ាន់នឹងសារុង ហើយយំនៅខាងក្រៅអាគារ នៅពេលលោកមើលពីមាត់ទ្វារទៅ។ លោកមិនដឹងថា មានអ្វីកើតឡើងចំពោះពួកគេនោះទេ តែទិដ្ឋភាពនេះ ធ្វើឲ្យគាត់នឹកក្នុងចិត្តភ្លាមថា សភាពការណ៍ដូចជាមិនស្រួល ធ្វើឲ្យគាត់កាន់តែភ័យខ្លាច ដូច្នេះ គាត់ក៏បានវិលត្រឡប់មកមន្ទីរពេទ្យវិញ។

លោក **មាស សារ៉ាន់** បានរៀបរាប់ពីស្ថានភាពនៅក្នុងបុរីកីឡានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យ៉ាងដូច្នេះថា៖ នៅបុរីកីឡា មានគ្រែសម្រាប់ដាក់អ្នកជម្ងឺតែ ៥០ទេ តែមានអ្នករងរបួសច្រើន មានក្មេង មានចាស់ ត្រូវបានគេយកទៅដាក់គរនៅក្បែរមាត់ទ្វារមន្ទីរពេទ្យ។ អ្នករងរបួសខ្លះ ក៏ស្លាប់ ហើយគ្មានអ្នកណាយកចេញទៅក្រៅទេ។ ដូច្នេះ ពួកគេក៏ប្រមូលសាកសពយកទៅដាក់នៅផ្នែកខាងលើមន្ទីរពេទ្យ ឯនៅខាងក្រោមដាក់អ្នករបួស ព្រោះវាមានច្រើនពេក។ ទោះជាយ៉ាងណាក្តី លោក **មាស សារ៉ាន់** បានផ្តល់សក្ខីកម្មថា បន្ទាប់ពីម៉ោង ៩ ឬ ១០ ព្រឹក មិនសូវមានអ្នករងរបួសច្រើនប៉ុន្មានទេ ខណៈពេលដែលបុគ្គលិកពេទ្យ ត្រូវតែនាំគ្នារត់ចេញអស់ដែរ។ ជាលទ្ធផល មានអ្នកជម្ងឺជាច្រើនទៀត ត្រូវបានគេទុកចោលដោយមិនបានព្យាបាល ។

## ខ.៤. ការចាកចេញពីទីក្រុងភ្នំពេញ

នៅវេលាប្រហែលជាម៉ោង ១០ ព្រឹក ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បុគ្គលិកពេទ្យ ត្រូវបានប្រាប់ថា មានយោធាគេប្រាប់ថាឲ្យពួកគាត់ត្រូវចាកចេញពីមន្ទីរពេទ្យឲ្យបានឆាប់ ព្រោះអាមេរិកនឹងទម្លាក់គ្រាប់បែកនៅម៉ុំនេះ។ ក្នុងចំណោមអ្នកជម្ងឺនៅក្នុងមន្ទីរពេទ្យ មានក្មេងស្រីតូចម្នាក់អាយុប្រមាណជា ៨ឆ្នាំ បានត្រូវរបួសធ្លាយពោះវៀនចេញមកក្រៅ។ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវញែក ការគិតរបស់ខ្លួនជាពីរ ម្យ៉ាងត្រូវព្យាបាលក្មេងស្រីតូចនេះ ដែលពេលនោះនាងមានតែម្នាក់ឯង គ្មានសាច់ញាតិណាម្នាក់ឡើយ ម្យ៉ាងគាត់ក៏កំពុងតែស្វែងរកភរិយារបស់ខ្លួនដែលមានផ្ទៃពោះ ប្រាំបីខែទៀត។ នៅទីបញ្ចប់ លោក **មាស សារ៉ាន់** បានសម្រេចចិត្តចាកចេញពីនាង បើទោះបីជា ក្មេងស្រីនោះអង្វរឲ្យយកនាងទៅជាមួយក៏ដោយ។ ដើមបណ្តឹងរដ្ឋប្បវេណីបានថ្លែងដូច្នេះថា "រុញពោះវៀនហ្នឹងចូលក្នុងរួចហើយ ខ្ញុំក៏បិទពោះហ្នឹងវិញទៅ ហើយមុខកូនហ្នឹង វានៅនឹងភ្នែកខ្ញុំដល់តែឥឡូវ"។

លោក **មាស សារ៉ាន់** បានព្យាយាមធ្វើដំណើរទៅដល់ភាគព្យសាន ដែលជាទីកន្លែងប្រពន្ធរបស់គាត់ធ្លាប់ស្នាក់នៅជាមួយសាច់ញាតិ ប៉ុន្តែគាត់ត្រូវបានគេបង្ខំឲ្យធ្វើដំណើរតាមផ្លូវជាតិលេខ១វិញ។ បន្ទាប់មក គាត់បានសម្រេចចិត្តធ្វើដំណើរទៅផ្ទះរបស់គាត់ នៅតាមបណ្តោយដងផ្លូវមួយនេះ ហើយដោយការភ័ន្តភាំងស្លន់ស្លោនឹងស្នូរគ្រាប់កាំភ្លើងផង ណាខ្លាច ស្ថានភាពជាទូទៅផង ធ្វើឲ្យគាត់មិនបានយកអ្វីតាមខ្លួន ក្រៅតែពីអាវមួយរបស់ប្រពន្ធគាត់ និងបានយកជាប់តាមខ្លួនរហូតដល់គាត់បានធ្វើដំណើរមកដល់ភូមិកំណើតប្រពន្ធ។

ដោយបានរួមរស់ជាមួយនឹងជនភៀសខ្លួនដទៃទៀតនៅពេលកំពុងធ្វើដំណើរតាមដងផ្លូវ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ឡើងវិញថា ទាហានខ្មែរក្រហមបានដើរល្បាតទាំងហ្វូងៗ ធ្វើឲ្យគាត់អាចស្តាប់ឮស្នូរបាញ់កាំភ្លើងមកពីគ្រប់ជ្រុង ដែលតាមការទាយរបស់គាត់ គឺស្នូរនោះចេញពីការបាញ់ទៅលើអាកាស (បាញ់ខ្យល់) ដោយទាហានទាំងនោះ។ លោក **មាស សារ៉ាន់** បានថ្លែងថា មនុស្សនាំគ្នាដើរទៅ "ទាំងហ្វូងដូចហ្វូងគោ" ហើយ "ចង្អៀតកកកុញ" នៅត្រឹមមហាវិថីព្រះមុនីវង្ស លោកក៏បានឃើញការវាយប្រយុទ្ធគ្នារវាងទាហានខ្មែរក្រហមប្រមាណជាប្រាំពីរ ទៅប្រាំបីនាក់ ជាមួយនឹងទាហាន **លន់ នល់** ដែលមិនព្រមដាក់អាវុធសុំចុះចាញ់។ ការវាយប្រយុទ្ធគ្នាបានបញ្ចប់ ដោយទាហាន **លន់ នល់** ម្នាក់នោះត្រូវបានបាញ់សម្លាប់។

លោក **មាស សារ៉ាន់** និងអ្នកដទៃទៀតបានសម្រេចចិត្តស្នាក់នៅក្រោមស្ពានព្រះមុនីវង្ស ដើម្បីរង់ចាំពេលវេលាសមគួរ នឹងអាចឲ្យពួកគាត់ត្រឡប់ទៅផ្ទះខ្លួនវិញ។ ក្នុងអំឡុងពេលស្នាក់នៅទីនោះ ទាហានខ្មែរក្រហមមិនបានជួយទំនុកបម្រុងណាមួយដល់ពួកគាត់ឡើយះ ចេញមិនទាន់ផុតពីក្រុងទេ។ តាមផ្លូវអត់មានអ្នកណាម្នាក់ប្រាប់ថា នែ៎នេះទឹក នេះបាយ ថ្នាំសង្កូវអី ឬ ក៏ស្អីមួយ អត់មានទេ។ ដើមបណ្តឹងរដ្ឋប្បវេណីបានថ្លែងឲ្យដឹងថា ខ្លួនរួចជីវិតមកបាន ដោយសារបានលួចយកស្ករខ្លះពីឃ្លាំង បូករួមនឹងសាច់ជ្រូកខ្លះ ដែលបានពីការចែកគ្នាជាមួយមនុស្សម្នាក់ផ្សេងទៀត ក្រោយពីបានសម្លាប់វាហើយ (ជ្រូករត់តាមផ្លូវអត់ម្ចាស់) គាត់ក៏យកមកអាំងទទួលទាន

ជាមួយបាយ (ខ្ញីឆ្នាំងអ្នកជិតខាងដាំ) និង ផឹកទឹកទន្លេ។ បន្ទាប់ពីនៅទីនោះបានបីថ្ងៃកន្លងផុតទៅ ដោយគ្មានការប្រកាស ណាមួយអនុញ្ញាតឲ្យប្រជាជនវិលត្រឡប់ទៅកាន់ទីក្រុងភ្នំពេញវិញ ដើមដើមបណ្តឹងប្បវេណីកាន់តែមានការសង្ស័យខ្លាំងឡើងៗ អំពីព័ត៌មានដែលថានឹងមានការទម្លាក់គ្រាប់បែកពីសំណាក់អាមេរិក។ ការសង្ស័យនេះបានបណ្តាលឲ្យលោក **មាស សារ៉ាន់** សម្រេចមិនឆ្លើយតប ឬ ស្តាប់តាមសេចក្តីប្រកាសនៅថ្ងៃទីបួន និងទីប្រាំតាមម៉េក្រូហ្វូន ដើម្បីអំពាវនាវឲ្យអ្នកដែលជាមន្ត្រីរដ្ឋការ ទាហាន និងមន្ត្រីយោធាជាន់ខ្ពស់ផ្សេងៗ ត្រឡប់ចូលទៅទីក្រុងភ្នំពេញវិញ ដើម្បីបន្តបម្រើការងាររបស់ខ្លួន ក្នុងការកសាងប្រទេសជាតិ ដោយសារតែសង្គ្រាមត្រូវបានបញ្ចប់ហើយ។ លោក **មាស សារ៉ាន់** បានឃើញក្រុមគ្រួសារមួយចំនួន បាននាំគ្នាវិលចូលទៅកាន់ទីក្រុងវិញ។ គាត់មិនឃើញអ្នកទាំងនោះត្រឡប់មកវិញទេ ប៉ុន្តែដោយសារតែខ្លួនគាត់ផ្ទាល់ មិនបានធ្វើតាមការអំពាវនាវនេះ លោកក៏មិនបានដឹងថា មានអ្វីកើតឡើងចំពោះពួកគេទាំងនេះដែរ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តរង់ចាំ កន្លែងចាស់នេះអស់រយៈពេលពីរសប្តាហ៍ ។

### *ខ.៥. អត្តចរិត និងភាពជឿជាក់នៃដើមបណ្តឹងរដ្ឋប្បវេណី*

លោក **មាស សារ៉ាន់** បានឆ្លើយតបទៅនឹងមេធាវីប្រឹក្សាក្តីរបស់គាត់ គឺលោកស្រី **ម៉ាទីល្ហ** ក្នុងលក្ខណៈលម្អិត និងជាទូទៅមានការស៊ីចង្វាក់គ្នាបានល្អ។ ទោះជាយ៉ាងណាក្តី គាត់ហាក់ដូចជា ស្តែងចេញនូវមនោសញ្ចេតនាក្តុកក្តួល នៅពេលដែលគាត់បានរៀបរាប់អំពីផលលំបាកក្នុងការសម្រេចជ្រើសរើសដ៏តឹងតែងមួយ រវាងការចង់ស្វែងរកប្រពន្ធ និងក្មេងស្រីតូចអាយុ៨ឆ្នាំ ដែលជាអ្នកជម្ងឺម្នាក់របស់គាត់នៅឯមន្ទីរពេទ្យ។ គាត់បានថ្លែងនៅក្នុងសក្ខីកម្មរបស់គាត់អំពីក្មេងស្រីនោះថា "ក្មេងស្រីដែលខ្ញុំជម្រាបអម្បាញ់មិញនេះ ខ្ញុំមានកម្មមានពៀរហ្នឹងវាហូត ពីព្រោះវានៅនឹងមុខខ្ញុំរហូត។ វាចាប់អាវខ្ញុំ វាថាឲ្យយកវាទៅផង វាចាប់អាវខ្ញុំជាប់។ ខ្ញុំមិនដឹងធ្វើម៉េចទេ ដូចនេះហើយ មុខកូនហ្នឹង នៅនឹងមុខខ្ញុំរហូតទល់ឥឡូវហ្នឹង"។

## ផ្នែកទី៣ ៖ បញ្ហានីតិវិធី និង ច្បាប់

សប្តាហ៍នេះ តុលាការបានប្រទះនូវបញ្ហានីតិវិធីផ្លូវច្បាប់មួយចំនួន ទាក់ទងនឹងស្ថានភាពសុខភាពរបស់លោក **អៀង សារី** និងនីតិវិធីក្នុងការសួរដេញដោលសាក្សី។ ឆ្លើយតបទៅនឹងសក្ខីកម្មរបស់លោកវេជ្ជបណ្ឌិត **ចន ខាំប៉ែល** កាលពីសប្តាហ៍មុន មេធាវីការពារក្តីរបស់លោក **អៀង សារី** បានស្នើឲ្យផ្អាកការសួរនាំអំពីសម្បទារបស់ជនជាប់ចោទសិន រហូតទាល់តែមានដំណោះស្រាយ ពោលគឺនៅពេលដែលមានសាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ អាចជាបុគ្គលសំខាន់ចំពោះករណីរបស់កូនក្តីខ្លួនចាប់ផ្តើមមកផ្តល់សក្ខីកម្ម។ មេធាវីអន្តរជាតិការពារក្តីលោក **អៀង សារី** គឺលោក **ម៉ៃខល កាណាវ៉ាស** បានសង្កត់ធ្ងន់នូវជំនឿរបស់លោក ថាកូនក្តីខ្លួន គឺមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការប្រកបដោយអត្ថន័យគ្រប់គ្រាន់ ផ្អែកតាមបទដ្ឋានអន្តរជាតិនោះទេ ខណៈដែលអង្គជំនុំជម្រះ ហាក់ដូចជាមិនសូវសាទរជាមួយនឹងយោបល់ ទាំងឡាយណាដែលជាសំណូមពរ សុំឲ្យ

មានការពន្យារពេលចេញសេចក្ដីសម្រេច (តើលោក **អៀង សារី** អាចមានសម្បទា ឬ មិនមានក្រោយស្ដាប់នូវលទ្ធផលនៃការធ្វើកោសល្យវិច្ច័យពីវេជ្ជបណ្ឌិត ដើម្បីឲ្យក្រុមខ្លួនអាចសម្រេចនូវគោលជំហរជាបន្តបន្ទាប់នាពេលខាងមុខទៀត)។ ទោះជាយ៉ាងនេះក្ដី មេធាវីការពារក្ដី បានទាញការចាប់អារម្មណ៍ឲ្យអង្គជំនុំជម្រះប្រយ័ត្នប្រយែងថា ប្រសិនបើអង្គជំនុំជម្រះសម្រេចចិត្តភ្លាមៗលើបញ្ហានេះ ក្រុមមេធាវីការពារក្ដីរបស់លោក **អៀង សារី** ប្រហែលត្រូវដាក់ចេញនូវលិខិតសុំលះបង់សិទ្ធិមិនស្ដាប់សក្ខីកម្មសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន ហើយត្រូវតែបង្ខំចិត្តពិចារណាអំពីការបំបែកសំណុំរឿងរបស់កូនក្ដីខ្លួន ដាច់ដោយឡែកពីជនជាប់ចោទផ្សេងទៀត។ ទាំងចិត្តមិនចង់ឬយ៉ាងណា ពោលគឺអ្វីដែលក្រុមខ្លួនធ្វើការស្នើសុំឲ្យមានការដោះស្រាយ ព្រោះមិនចង់ឲ្យមានការរាំងស្ទះដល់ដំណើរការនីតិវិធី។ ដូច្នេះ មេធាវីបានស្នើសុំឲ្យអង្គជំនុំជម្រះ ចាប់ផ្ដើមស្ដាប់សក្ខីកម្មរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនដែលពុំទាមទារឲ្យមានការចូលរួមពីលោក **អៀង សារី** ក្នុងពេលស្ថានភាពរបស់គាត់នៅតែមិនទាន់ប្រសើរនៅឡើយ។ វិធានការទាំងនេះ បានផ្ដល់ឲ្យសុខភាពទន់ខ្សោយរបស់ជនជាប់ចោទ ឈានទៅរកការប្រឈម នឹងការអូសបន្លាយពេលការជំនុំជម្រះក្ដីនេះកាន់តែច្រើន។ បញ្ហាច្បាប់ផ្សេងទៀត ដែលគួរឲ្យកត់សម្គាល់ផងដែរក្នុងសប្ដាហ៍នេះ ជាញឹកញាប់កើតមានឡើងក្នុងអំឡុងពេលសួរដេញដោលសាក្សី រាប់បញ្ចូលទាំងការសួរសំណួរអំពីភាពត្រឹមត្រូវនៃកំណត់ត្រាបទសម្ភាសន៍ ធ្វើឡើងដោយបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេត របៀបនៃការប្រើប្រាស់ឯកសារនៅពេលដាក់បង្ហាញនៅចំពោះមុខសាក្សី ដើម្បីសួរសំណួរផ្អែកលើឯកសារទាំងនេះ ក៏ដូចជា ការរក្សាឲ្យបាននូវដែនកំណត់នៃសំណួរឲ្យនៅត្រឹមវិសាលភាពនៃសំណុំរឿង០០២/០១។

## ក. ការឆ្លើយតបរបស់ភាគី ចំពោះសក្ខីកម្មអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ

នៅថ្ងៃចន្ទ អង្គជំនុំជម្រះបានផ្ដល់ឱកាសឲ្យក្រុមមេធាវីការពារក្ដីរបស់ជនជាប់ចោទ **អៀង សារី** ភាគីសហព្រះរាជអាជ្ញា និងក្រុមមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បង្ហាញនូវជំហររបស់ពួកគេ ដោយធ្វើការឆ្លើយតបទៅនឹងសក្ខីកម្មរបស់លោកវេជ្ជបណ្ឌិត **ចន ខាំប៊ែល** បន្ទាប់ពីលោកវេជ្ជបណ្ឌិត បានមកផ្ដល់សក្ខីកម្មទាក់ទងនឹងរបបគំហើញ ស្ដីពីបញ្ហាសម្បទារបស់ជនជាប់ចោទ **អៀង សារី** កាលពីថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០១២ ។[13] លោកមេធាវី **កាណាវ៉ាស** បានជូនជាយោបល់ថា វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការ "ស្វែងរកដំណោះស្រាយដែលអាចទទួលយកបាន និងប្រកបដោយយុត្តិធម៌"[14] ចំពោះស្ថានភាពសុខភាព និងសម្បទារបស់របស់កូនក្ដីខ្លួន បើទោះជារហូតមកដល់ចំណុចនេះ ក្រុមការពារក្ដីរបស់ខ្លួនមិនទាន់បានដាក់ពាក្យស្នើសុំឲ្យបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងលោក **អៀង សារី** នៅឡើយក្ដី ហើយខណៈដែលបច្ចុប្បន្ននេះ គាត់មានអាយុ ៨៩ឆ្នាំ ដែលស្ថានភាពសុខភាពរបស់គាត់ក៏មិនទៀងទាត់ទៀត។ លោក **កាណាវ៉ាស** បានសង្កត់ធ្ងន់ថា បញ្ហាស្ដីពីសមត្ថភាពនៃការផ្ចង់អារម្មណ៍បានរបស់កូនក្ដីខ្លួន ត្រូវតែដោះស្រាយដោយយកចិត្តទុកដាក់ ដោយពិចារណាទៅលើសិទ្ធិក្នុងការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌របស់លោក **អៀង សារី** ដូចមានចែងនៅក្នុងមាត្រា៣១ និងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)។[15] ទោះជាយ៉ាងណាក៏ដោយ មេធាវីបានបន្តថា ការពិភាក្សាគ្នាអំពីបញ្ហានេះក្នុងពេលឥឡូវនេះ "អាចនឹងលឿនពេក"។ លោក **កាណាវ៉ាស** បានថ្លែងឲ្យដឹងថា លោក **អៀង សារី** បានលះបង់សិទ្ធិក្នុងការមានវត្តមាន

ក្នុងពេលសួរដេញដោលទៅលើសាក្សីមួយចំនួន ដែលគ្រោងនឹងមកផ្តល់សក្ខីកម្មនៅអំឡុងខែវិច្ឆិកា ដូច្នេះ មានន័យថា កិច្ចដំណើរការនីតិវិធីនៅតែអាចបន្តទៅបាន ដោយមិនចាំបាច់មានវត្តមានកូនក្តីរបស់គាត់ចូលរួមស្តាប់។

ទាក់ទងនឹងសក្ខីកម្មរបស់លោកវេជ្ជបណ្ឌិត **ចន ខាំប៊ែល** លោកមេធាវី **កាណាវ៉ាស** បានថ្លែងឲ្យដឹងថា ក្រុមមេធាវីរបស់ខ្លួន នឹងមិនធ្វើលិខិតរៀបរាប់លម្អិតនូវការជំទាស់នានាក្នុងពេលនេះឡើយ ដោយសារគ្មានពេលវេលាគ្រប់គ្រាន់ដើម្បីអាននូវអង្គសេចក្តីទាំងស្រុងនៃសក្ខីកម្មរបស់វេជ្ជបណ្ឌិត ប៉ុន្តែបានឆ្លើយតបទៅនឹងកោសល្យវិច្ច័យរបស់លោកវេជ្ជបណ្ឌិតភ្លាមៗថា ជាការសន្និដ្ឋាន "បែបច្នៃប្រឌិត"។ លោក **កាណាវ៉ាស** បានចង្អុលបង្ហាញពីភាពខុសគ្នាដាច់ស្រឡះ រវាងការពិពណ៌នារបស់វេជ្ជបណ្ឌិត **ចន ខាំប៊ែល** ទៅលើបញ្ហាសុខភាពរបស់លោក **អៀង សារី** (ដែលថា ស្ថានភាពសុខភាពរបស់លោក **អៀង សារី** មិនធ្ងន់ធ្ងរ) និងការសង្កេតរបស់លោកខ្លួនឯង នៅពេលដែលគាត់ទៅជួបផ្ទាល់ជាមួយកូនក្តីខ្លួន។ មេធាវីការពារក្តីលោក **អៀង សារី** បានសុំឲ្យអង្គជំនុំជម្រះ ចាប់អារម្មណ៍លើយោបល់ទីពីរ ដែលត្រូវតែស្វែងរកដំណោះស្រាយ និងបានជំរុញឲ្យអង្គជំនុំជម្រះ ធ្វើការកោះហៅលោកវេជ្ជបណ្ឌិត **ប៊ូសចាន** ដែលបានផ្តល់នូវការវាយតម្លៃលើកដំបូងជាមូលដ្ឋានលើផ្នែកវេជ្ជសាស្ត្រ (ដោយស្ម័គ្រចិត្ត) ហើយនិងត្រូវបានដាក់ជូនអង្គជំនុំជម្រះកាលពីពេលកន្លងទៅ។[16] លោក **កាណាវ៉ាស** បានស្នើថា អង្គជំនុំជម្រះ គួរតែពិចារណាផ្តល់ព័ត៌មានដែល វេជ្ជបណ្ឌិត **ចន ខាំប៊ែល** មាន ទៅឲ្យទៅលោកវេជ្ជបណ្ឌិត **ប៊ូសចាន** ដើម្បីផ្តល់ឱកាសឲ្យគាត់ធ្វើការវាយតម្លៃនូវស្ថានភាពសុខភាពរបស់លោក **អៀង សារី** ដោយឯករាជ្យ។ លោក **កាណាវ៉ាស** បានបញ្ចប់ជាមួយនឹងការធានាថា ក្រុមមេធាវីការពារក្តីរបស់លោក **អៀង សារី** នឹងមិនជំទាស់ឡើយ ប្រសិនបើភាគីផ្សេងៗទៀត មានបំណងចង់ចាត់ចែងឲ្យមានអ្នកជំនាញផ្ទាល់ខ្លួនតាមការចង់បានរបស់ពួកគេ ហើយក៏បានសួរទៅកាន់អង្គជំនុំជម្រះផងដែរថា តើអង្គជំនុំជម្រះចង់ឲ្យក្រុមខ្លួនស្នើជាលាយលក្ខណ៍អក្សរទាក់ទងនឹងការតែងតាំងអ្នកជំនាញថ្មីឬយ៉ាងណា (**ប៊ូសចាន**) និងថាពួកគេនឹងធ្វើតាម ប៉ុន្តែបើអង្គជំនុំជម្រះសាលាដំបូងបដិសេធមិនទទួលយកសំណើរបស់ពួកគេ មេធាវីបានស្នើថា អង្គជំនុំជម្រះគួរចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយមានសម្អាងហេតុ។

ការឆ្លើយតបរបស់លោកមេធាវី **កាណាវ៉ាស** ជាហូរហែនេះ បាននាំឲ្យចៅក្រមនៃអង្គជំនុំជម្រះ ស្នើសុំឲ្យមេធាវីជួយបំភ្លឺនូវចំណុចជាក់លាក់ផ្សេងៗទៀត។ សហចៅក្រម រួមមានលោកស្រី **ស៊ីលវៀ ខាតវ៉ាយថ៍** និង លោកចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** បានសួរទៅកាន់មេធាវីអន្តរជាតិរបស់លោក **អៀង សារី** គឺលោក **កាណាវ៉ាស** ឲ្យធ្វើការគូសបញ្ជាក់ពីជំហរស្តីពីសម្បទារបស់ជនជាប់ចោទ។

លោក **កាណាវ៉ាស** បានរក្សាជំហរពីរដែលក្រុមការពារក្តីខ្លួនតែងតែមានគឺថា ពួកគេមិនចាត់ទុកថា កូនក្តីខ្លួនមានសម្បទាគ្រប់គ្រាន់នោះទេ ហើយបើទោះជា គាត់ត្រូវតែតម្រូវឲ្យចូលរួមក្នុងសវនាការ ក៏ការចូលរួមនេះមិនប្រកបដោយអត្ថន័យដែរ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង យល់ស្របជាមួយនឹងសក្ខីកម្មរបស់លោកវេជ្ជបណ្ឌិត **ចន ខាំប៊ែល** ដែលថាលោក **អៀង សារី** ជាធម្មតាគ្រាន់តែត្រូវយកចិត្តទុកដាក់ស្តាប់ (បើគាត់ដោក ឲ្យ

ដាស់គាត់ឲ្យភ្ញាក់) លោក **កាណាវ៉ាស** បានតតាំងនឹងការលើកឡើងនេះ ដោយបានស្នើសុំឲ្យនាំខ្លួនលោក **អៀង សារី** សម្រាន្តលើគ្រែ យកចូលមកក្នុងបន្ទប់សវនាការ អំឡុងពេលកំពុងដំណើរការនីតិវិធី ដើម្បីឲ្យសាធារណជនអាចមើលឃើញ ថាតើកូនក្តីគាត់ពិតជាអាចចូលរួមសវនាការមែន ឬ អត់។ លោកមេធាវីបានរៀបរាប់ថា តាមពិសោធន៍របស់គាត់ផ្ទាល់ នៅពេលចូលទៅពិភាក្សាលើអង្គហេតុមួយចំនួនជាមួយលោក **អៀង សារី** បានបង្ហាញថា លោក **អៀង សារី** អាចផ្ចង់អារម្មណ៍កំណត់ត្រឹមរយៈពេលពី៥ ទៅ១៥ នាទីតែប៉ុណ្ណោះ ដូច្នេះ មេធាវីបានស្នើថា ការចូលរួមក្នុងរយៈពេលនេះ គឺមិនមានន័យថា កូនក្តីគាត់អាចចូលរួមក្នុងដំណើរការនីតិវិធីជំនុំជម្រះរឿងក្តីរបស់ខ្លួនប្រកបដោយអត្ថន័យឡើយ។ ទោះជាយ៉ាងណាក៏ដោយ លោក **កាណាវ៉ាស** បានពន្យល់ថា ក្រុមការពារក្តី នឹងជំរុញឲ្យប្រើនូវវិធានការដែលអាចវាស់វែង (ធ្វើទៅរួច) បានមួយ។ លោកបានរម្លឹកឡើងវិញថា លោក **អៀង សារី** បានលះបង់ សិទ្ធិរបស់គាត់ មិននៅតទល់ជាមួយនឹងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់មួយចំនួនរួចទៅហើយ ហើយដែលប្រការនេះ នឹងអនុញ្ញាតឲ្យអង្គជំនុំជម្រះអាចប្រើប្រាស់ពេលវេលានេះ សម្រាប់ស្តាប់សក្ខីកម្មពីបុគ្គលជាក់លាក់ទាំងនោះបាន របហូតដល់សុខភាពរបស់កូនក្តីខ្លួនល្អប្រសើរឡើងវិញ។ នៅពេលដែលមានសាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណីសំខាន់ណាម្នាក់ ដែលត្រូវតែកោះហៅឲ្យមកផ្តល់សក្ខីកម្ម ហើយដែលសក្ខីកម្មរបស់អ្នកទាំងនេះ គឺធ្វើឡើងដើម្បីប្រឆាំងនឹង លោក **អៀង សារី** នោះ បញ្ហាសម្បទារបស់កូនក្តីខ្លួនក្នុងការចូលរួមការជំនុំជម្រះក្តីត្រូវតែយកមកពិភាក្សាជាថ្មីម្តងទៀត ពោលគឺ អាស្រ័យលើស្ថានភាពសុខភាពរបស់ជនជាប់ចោទ។ លោក **កាណាវ៉ាស** បានថ្លែងថា ការរៀបចំបែបនេះ នឹងជួយពន្លឿនដំណើរការនីតិវិធីបាន។ មេធាវីអន្តរជាតិការពារក្តីរបស់លោក **អៀង សារី** រូបនេះ ក៏បានជានាចំពោះលោកចៅក្រម **ឡាវ៉ែន** ផងដែរថា លោក **អៀង សារី** បានណែនាំឲ្យមេធាវីការពារក្តី ឲ្យធ្វើលិខិតលះបង់សិទ្ធិចូលរួមដោយពេញទៅតាមឆន្ទៈ និងភាពវាងវៃ ព្រោះតែគាត់អាចផ្ចង់អារម្មណ៍បានតែក្នុងរយៈពេលដ៏ខ្លីមួយតែប៉ុណ្ណោះ នាពេលបច្ចុប្បន្ន។

នៅក្នុងការឆ្លើយតបទៅនឹងសក្ខីកម្មរបស់លោកវេជ្ជបណ្ឌិត **ចន ខាំប៊ែល** សហព្រះរាជអាជ្ញា អន្តរជាតិលោក **វីល្លីម ស្មីត** បានកត់សម្គាល់ថា ខណៈដែលស្ថានភាពកាយសម្បទារបស់ **អៀង សារី** កំពុងស្ថិតក្នុងភាពធុយស្រួយ និងបានបដិសេធតាំងពីថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១២ មកម្ល៉េះ ថា ស្ថានភាពសុខភាពរបស់គាត់ គឺមិនមានលក្ខខណ្ឌគ្រប់គ្រាន់ដែលអាចចេញពីមន្ទីរពេទ្យបានឡើយ។ ព្រះរាជអាជ្ញា **ស្មីត** បានថ្លែងថា អ្វីដែលអង្គជំនុំជម្រះសាលាដំបូងទទួលបាន គឺជនជាប់ចោទ ដែលមានសុខភាពទន់ខ្សោយ ប៉ុន្តែស្របពេលជាមួយគ្នានេះ គាត់ក៏ជាមនុស្សម្នាក់ដែលត្រូវបានរកឃើញដោយវេជ្ជបណ្ឌិត **ចន ខាំប៊ែល** ថា "មានសម្បទាគ្រប់គ្រាន់នៅក្នុងការចូលរួមសវនាការ"។[17] ទាក់ទងនឹងការលើកឡើងរបស់លោកមេធាវី **កាណាវ៉ាស** ដែលបានផ្តល់យោបល់ថាឲ្យនាំយកលោក **អៀង សារី** មកកាន់បន្ទប់សវនាការ លោក **ស្មីត** យល់ឃើញថា វាជារឿងមិនសមរម្យ ពីព្រោះថា ការធ្វើដូចនេះ នឹងមិនបានផ្តល់ឲ្យជនជាប់ចោទនូវភាពងាយស្រួលជាចាំបាច់នៅពេល ដែលគាត់ស្ថិតក្នុងស្ថានភាពបែបនេះ។ ព្រះរាជអាជ្ញាអន្តរជាតិយល់ព្រមជាមួយនឹងអនុសាសន៍របស់លោកវេជ្ជបណ្ឌិត **ចន ខាំប៊ែល** ដែលថា លោក **អៀង សារី** គួរតែបន្តចូលរួមតាមដានដំណើរការនីតិវិធីតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំខ្លួន (តាមដានពីចម្ងាយ)។ ព្រះរាជអាជ្ញា **ស្មីត** បានសម្តែងនូវទំនុកចិត្ត លើរូបលោកវេជ្ជបណ្ឌិត **ចន ខាំប៊ែល** ថាជាសាស្ត្រាចារ្យ

មួយរូប ដែលពោរពេញទៅដោយបទពិសោធន៍ផ្នែកឱសថសាស្ត្រសម្រាប់មនុស្សចាស់ និងអនុសាសន៍នានារបស់លោកវេជ្ជបណ្ឌិតចំពោះស្ថានភាពសុខភាពជនជាប់ចោទ **អៀង សារី** គឺសមហេតុផល។

លោក **ស្មីត** បានរម្លឹកអង្គជំនុំជម្រះថា បញ្ហាដែលកំពុងមាននៅក្នុងដៃពេលនេះ គឺមិនមែនអំពីចំនួននៃបញ្ហាសុខភាពអ្វីខ្លះដែលលោក **អៀង សារី** មាននោះទេ ប៉ុន្តែសំខាន់ ថាតើជនជាប់រូបនេះអាចមានសម្បទាស្មារតីគ្រប់គ្រាន់ ឬ អត់។[18] ព្រះរាជអាជ្ញាអន្តរជាតិរូបនេះ ក៏បានរម្លឹក អង្គជំនុំជម្រះផងដែរថា មិនមានភស្តុតាងពិតប្រាកដណាមួយដែលបង្ហាញពីការធ្លាក់ចុះសមត្ថភាព ផ្លូវចិត្តរបស់លោក **អៀង សារី** នៅឡើយទេ បើគិតចាប់ពីខែកញ្ញា ដល់ខែវិច្ឆិកា។ យោងតាមសេចក្តីសម្រេចលើសំណុំរឿង ស្រ្វូហ្គា[19] របស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ សមត្ថភាពចំនួន៧ របស់លោក **អៀង សារី** បានកំណត់ពីសម្បទាក្នុងការចូលរួមការសវនាការ ត្រូវបានធ្វើតេស្តសាកល្បង ហើយដែលជាលទ្ធផល ជនជាប់ចោទបានជាប់ ឬ ឆ្លងកាត់បាននូវការធ្វើកោសល្យវិច្ច័យកាលពីខែកញ្ញា និងខែវិច្ឆិកា។ ព្រះរាជអាជ្ញាបានស្នើអង្គជំនុំជម្រះសាលាដំបូងឲ្យធ្វើការ សម្រេចដោយផ្អែកលើភស្តុតាងដែលមានក្នុងដៃ និងមិនចាំបាច់រាប់បញ្ចូលនូវអនុសាសន៍របស់មេធាវីការពារក្តីលោក **អៀង សារី** ឬ សេចក្តីសន្និដ្ឋាននៅក្នុងសារអេឡិចត្រូនិចរបស់លោក វេជ្ជបណ្ឌិត **ប៊ូសចាន**។[20]

ទាក់ទងទៅនឹងសំណើរបស់លោកមេធាវី **កាណាវ៉ាស** ដែលស្នើអង្គជំនុំជម្រះឲ្យធ្វើការពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិត **ប៊ូសចាន** ព្រះរាជអាជ្ញាអន្តរជាតិ **ស្មីត** បានយល់ឃើញថា វាជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង និងថាជនជាប់ចោទត្រូវបានធ្វើកោសល្យវិច្ច័យរួចហើយ ពីសំណាក់ក្រុមវិជ្ជបណ្ឌិតជំនាញបីរូប[21] នៅក្នុងរយៈពេលពីរខែនេះ ហើយដែលរាល់ដងនៃការពិនិត្យនោះត្រូវបានទទួលលទ្ធផលដូចគ្នា ពោលគឺថា លោក **អៀង សារី** មានកាយសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមស្តាប់សវនាការ។ ព្រះរាជអាជ្ញាបានចោទជាសំណួរពីភាពចាំបាច់នៃការកោះហៅ ឲ្យមានអ្នកជំនាញថ្មីមកធ្វើកោសល្យវិច្ច័យលើជនជាប់ចោទ នៅពេលដែលរកមិនឃើញមានការប្រែប្រួលសំខាន់ណាមួយទាក់ទងនឹងសមត្ថភាពផ្លូវចិត្តរបស់ជនជាប់ចោទនៅឡើយនោះ ហើយ លោកក៏បានព្រមានអង្គជំនុំជម្រះគួរតែប្រយ័ត្នប្រយែងថា វាអាចនឹងមានការកោះហៅវេជ្ជបណ្ឌិត ជំនាញថ្មីៗមកជាបន្តបន្ទាប់ទៀតគ្មានទីបញ្ចប់ រាល់ពេលដែលមានភាគីណាមួយនៃសំណុំរឿងនេះ មិនពេញចិត្តនឹងលទ្ធផលនៃការរកឃើញ។

ទាក់ទងនឹងសំណើរបស់លោក **កាណាវ៉ាស** ដែលស្នើអង្គជំនុំជម្រះសាលាដំបូងឲ្យពន្យារពេលចេញសេចក្តីសម្រេចទៅលើសម្បទារបស់លោក **អៀង សារី** ក្នុងការចូលរួមសវនាការរហូត ទាល់តែមានភាពចាំបាច់ណាមួយតម្រូវនោះ។ ដោយឡែក ព្រះរាជអាជ្ញា **ស្មីត** បានទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះ និងភាគីឲ្យមានការប្រយ័ត្នប្រយែងថា នេះជាសំណើដ៏គ្រោះថ្នាក់មួយ ព្រោះវាអាចជាមូលដ្ឋានដែលនាំឲ្យមានបណ្តឹងឧទ្ធរណ៍ពីក្រុមនេះនៅថ្ងៃក្រោយទៀត។ ព្រះរាជអាជ្ញាបានស្នើឡើងថា អង្គជំនុំជម្រះសាលាដំបូងគួរចេញសេចក្តីសម្រេចលើបញ្ហា

សុខភាពរបស់ជនជាប់ចោទ **អៀង សារី** និងសម្រេចណែនាំឲ្យមានការធ្វើកោសល្យវិច្ច័យឡើងវិញ ប្រសិនបើស្ថានភាពរបស់គាត់មានការប្រែប្រួលណាមួយនាពេលខាងមុខ ។

សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **អេលីហ្សាប៊ែត ស៊ីម៉ូនណូហ្វត** បានយល់ស្របទាំងស្រុងជាមួយនឹងជំហររបស់ព្រះរាជអាជ្ញា។ លោកស្រីបានទទូចថា ក្រុមការពាររបស់លោក **អៀង សារី** មិនបានផ្តល់នូវការជជែកតវ៉ាណាមួយផ្នែកវេជ្ជសាស្ត្រ ដើម្បីបង្ហាញពីការប្រឆាំងនឹងសេចក្តីសន្និដ្ឋានរបស់លោកវេជ្ជបណ្ឌិត **ចន ខាំប៊ែល** ឡើយ ប៉ុន្តែក្រុមនេះ ហាក់ដូចជាតវ៉ាតែលើបញ្ហាដែលថា លោកបណ្ឌិត **ចន ខាំប៊ែល** មានភាពលម្អៀងប្រឆាំងនឹងលើលោក **អៀង សារី**។ លោកស្រីបានបន្តរម្លឹកអង្គជំនុំជម្រះសាលាដំបូងថា អ្នកជំនាញផ្នែកសុខភាព មនុស្សចាស់រូបនេះ កន្លងទៅធ្លាប់បានធ្វើកោសល្យវិច្ច័យលើលោកស្រី **អៀង ធីរិទ្ធ** ម្តងរួចហើយ និងបានរកឃើញជាមូលដ្ឋានថា លោកស្រី **អៀង ធីរិទ្ធ** មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួម ការសវនាការទេ។ លោកស្រីមេធាវី ក៏បានគូសបញ្ជាក់ផងដែរថា ជនជាប់ចោទ **អៀង សារី** មានកាតព្វកិច្ចចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណជនក្នុងការចូលរួមការជំនុំជម្រះក្តីនេះ។

ឆ្លើយតបនឹងការលើកឡើងពីភាគីសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកមេធាវី **កាណាវ៉ាស** ជាបឋមបានចង្អុលបង្ហាញថា អ្វីដែលបានកើតឡើងចំពោះ លោកស្រី **អៀង ធីរិទ្ធ** គឺគ្មានការជាប់ពាក់ព័ន្ធអ្វីនឹងក្រុមមេធាវីការពារក្តីរបស់លោកទេ ពីព្រោះ លោកស្រី **អៀង ធីរិទ្ធ** មិនមែនជាកូនក្តីរបស់គាត់ទេ។ លោកក៏បានធានាអះអាងចំពោះអង្គជំនុំជម្រះថា ក្រុមមេធាវីការពារក្តីរបស់លោក **អៀង សារី** មិនពាក់ព័ន្ធនៅក្នុងការប្រើយុទ្ធសាស្ត្រណាមួយ ដើម្បីរៀបចំមូលដ្ឋានទុកប្តឹងឧទ្ធរណ៍ ដោយនាំឲ្យមានការយឺតយ៉ាវ ឬ រកមើលទោសកំហុសពីកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនោះទេ។ ទោះជាយ៉ាងណាក្តី លោក **កាណាវ៉ាស** បានព្រមានថា ប្រសិនបើអង្គជំនុំជម្រះចេញសេចក្តីសម្រេចឲ្យកូនក្តីគាត់ថា មានសម្បទាសមស្របនឹងចូលរួមការជំនុំជម្រះក្តីលទ្ធផលនេះនឹងបង្ខំឲ្យក្រុមមេធាវីការពារក្តី ត្រូវតែពិភាក្សាគ្នាជាមួយលោក **អៀង សារី** ដើម្បីដកចេញលិខិតលះបង់សិទ្ធិ ព្រមទាំងធ្វើការធានាថាជនជាប់ចោទត្រូវមានវត្តមានពេញលេញនៅក្នុងបន្ទប់សវនាការ ឬ តាមរយៈប្រព័ន្ធសោតទស្សន៍ ហើយស្នើភ្ជាប់វីដេអូដើម្បីមើលឃើញលោក **អៀង សារី** ពីក្នុងបន្ទប់ឃុំខ្លួនបាន។ លោក **កាណាវ៉ាស** បានថ្លែងយ៉ាងខ្លាំងក្លាថា លោកមិនចង់ចូលរួមនៅក្នុងកន្លែងមួយដែលភាគីនាំគ្នា "ច្រៀងល្ខោនផ្តោះផ្តងប្រស្នា" នៅពេលដែលកូនក្តីរបស់លោកសម្រាកនៅក្នុងបន្ទប់ឃុំខ្លួន (ជាមួយនឹងប្រព័ន្ធសោតទស្សន៍) តែមិនមាននរណាម្នាក់បានដឹង ថាតើជនជាប់ចោទរូបនេះកំពុងតែតាមដាន ឬ កំពុងតែងោក ឬ សម្រាន្តលក់ ឬគាត់អស់កម្លាំង ។ រួមសេចក្តីមក មេធាវីបានទាមទារធ្វើយ៉ាងណា ឲ្យមានការភ្ជាប់ប្រព័ន្ធវីដេអូ ពីបន្ទប់សោតទស្សន៍ មកសាលសាធារណៈ ដើម្បីឲ្យគ្រប់គ្នាមើលឃើញស្ថានភាពរបស់ជនជាប់ចោទ ថាតើគាត់បានចូលរួមពេញលេញដែរឬទេ។

ទាក់ទងនឹងសមត្ថភាពចូលរួមសវនាការឲ្យបានពេញលេញរបស់កូនក្តីខ្លួន មេធាវី **កាណាវ៉ាស** បានដកស្រង់កថាខណ្ឌ ៥៥ នៃសេចក្តីសម្រេចពីតុលាការឧទ្ធរណ៍របស់ អាយ.ស៊ី.ធី.វ៉ាយ ក្នុងសំណុំរឿង ស្រ្ទូហ្កា ។ មេធាវីបានផ្តល់យោបល់ថា បទពិសោធន៍នៃសំណុំរឿង មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមបទដ្ឋានដែលបានកំណត់ដោយអង្គជំនុំជម្រះនៃតុលាការ អាយ.ស៊ី.ធី.វ៉ាយ។ លោកមេធាវីបានហៅការប្តេជ្ញាចិត្តរបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ថាជាស្តង់ដារនៃការចូលរួមប្រកបដោយអត្ថន័យ ហើយគួរតែត្រូវបានចាត់ទុកថា សមហេតុផល និងមានសុភនិច្ឆ័យនៅក្នុងកម្រិតមួយដែលអាចធ្វើទៅបាន ដើម្បីកំណត់បានថា តើជនជាប់ចោទពិតជាអាចចូលរួមសវនាការដែរ ឬទេ?[22] ដោយយោងទៅលើភាពភ្លាំងភ្លាត់ក្នុងការផ្ចង់អារម្មណ៍ បូករួមនឹងការឈឺចាប់លើរាងកាយជាប្រចាំរបស់កូនក្តីខ្លួន មេធាវី **កាណាវ៉ាស** បានលើកឡើងថា ដោយពិចារណាលើពាក្យ “សុភនិច្ឆ័យ” ដូចការអនុវត្តក្នុងសេចក្តីសម្រេចរបស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ លើសំណុំរឿង ស្រ្ទូហ្កា វាច្បាស់ណាស់ដែលលោក **អៀង សារី** មិនមានសមត្ថភាពពេញលេញនឹងតាមដានកិច្ចដំណើរការនីតិវិធីសវនាការឡើយ ។

នៅក្នុងដំណាក់កាលចុងក្រោយនៃការជជែកលើរឿងរ៉ាវខាងលើនេះ លោកស្រីចៅក្រម **ខាតវ៉ាយថ៍** បានសម្តែងនូវការព្រួយបារម្ភអំពីការលើកសំណើរបស់មេធាវីការពារក្តី ដែលបានស្នើថា សវនាការគួរតែបន្តទៅមុខដោយមិនចាំបាច់មានសេចក្តីសម្រេចលើសម្បទារបស់លោក **អៀង សារី** ក្នុងការចូលរួមសវនាការ ខណៈពេលជាមួយគ្នា មេធាវីការពារក្តីក្រុមនេះ បានអះអាងថា កូនក្តីខ្លួនគឺមិនមានសម្បទាគ្រប់គ្រាន់ទៅទៀត។ យោងតាមលោកស្រី ចៅក្រម **ខាតវ៉ាយថ៍** វាមានន័យថា អង្គជំនុំជម្រះបាននឹងបន្តធ្វើសវនាការ បើទោះណាជាជនជាប់ចោទ **អៀង សារី** មិនមានសម្បទាគ្រប់គ្រាន់ចូលរួមសវនាការក្តី។ លោក **កាណាវ៉ាស** បានពន្យល់ដល់លោកស្រីចៅក្រមថា គាត់នៅតែមានសង្ឃឹមថា កូនក្តីរបស់លោកនឹងទទួលបានស្ថានភាពសុខភាពល្អប្រសើរជាងមុន ប៉ុន្តែអង្គជំនុំជម្រះ គួរតែអាចធ្វើសវនាការបានលើផ្នែកមួយចំនួនដែលលោក **អៀង សារី** បានលះបង់សិទ្ធិមិនចូលរួម ឬនិយាយម្យ៉ាងទៀតថា សវនាការអាចប្រព្រឹត្តទៅបានលើផ្នែកណាដែលមិនចាំបាច់មានវត្តមានរបស់ជនជាប់ចោទ **អៀង សារី**។ ជាថ្មីម្តងទៀត មេធាវីការពារក្តីបានព្រមានថា បើសិនអង្គជំនុំជម្រះ នៅតែទទូចចង់ចេញសេចក្តីសម្រេចថា លោក **អៀង សារី** មានសម្បទាអាចចូលរួមសវនាការបាន នោះក្រុមមេធាវីការពារក្តីនឹងណែនាំឲ្យលោក **អៀង សារី** ដកចេញនូវលិខិតលះបង់សិទ្ធិមានវត្តមាន និងទាមទារឲ្យមានការភ្ជាប់ប្រព័ន្ធវីដេអូពីបន្ទប់ឃុំខ្លួននៅខាងក្រោម ក្នុងពេលកំពុងដំណើរការនីតិវិធីសវនាការ ដើម្បីឲ្យគ្រប់គ្នាបានមើលឃើញនូវគ្រប់ស្ថានភាពទាំងអស់របស់លោក **អៀង សារី** ថាតើគាត់ពិតជាអាចចូលរួមសវនាការប្រកបដោយអត្ថន័យ និងពេញលេញដែរឬទេ (តើជនជាប់ ចោទមានសភាពវិលមុខ ឬ ធឹងធោងដែរឬទេ? ត្រូវដោះស្រាយដូចម្តេច បើជនជាប់ចោទងោក ឬ អស់កម្លាំង? តើត្រូវប្រកាសសម្រាកពី១០ទៅ១៥នាទី មុននឹងបន្តដំណើរការនីតិវិធីទៀត ឬយ៉ាងណា?)។ ស្តាប់ការអះអាងនេះចប់ ប្រធានតុលាការ លោកចៅក្រម **និល ណុន** បានបិទសវនាការស្តាប់ការឆ្លើយតបពីភាគីចំពោះសក្ខីកម្មរបស់លោកវេជ្ជបណ្ឌិត **ចន ខាំប៊ែល** និងបានប្រកាសថា សេចក្តីសម្រេចលើបញ្ហានេះ នឹងធ្វើក្នុងពេលវេលាសមស្របណាមួយខាងមុខ។

## ខ. ការអនុវត្តចំពោះការដាក់បង្ហាញឯកសារដល់សាក្សីដែលគាត់មិនធ្លាប់បានឃើញ

ជាថ្មីម្តងទៀត អង្គជំនុំជម្រះសាលាដំបូងបានប្រឈមនឹងសំណួរស្តីពីពិធីការនៃការដាក់បង្ហាញឯកសារនៅចំពោះមុខសាក្សីក្នុងអំឡុងពេលប្រព្រឹត្តទៅនៃដំណើរការនីតិវិធីសវនាការ។ ក្នុងពេលសួរដេញដោលទៅលើសាក្សី **ប៉េជុយ ធីបសៃ** ព្រះរាជអាជ្ញា **ខេល លីសាក់** បានពិគ្រោះយោបល់លើចំណារក្នុងបទសម្ភាសន៍មួយរវាងសាក្សី និងលោក **ហង់រី ឡូកា** ដែលបានធ្វើឡើងកាលពីខែកក្កដា ឆ្នាំ១៩៩១ ហើយដែលឯកសារនេះ សាក្សី **ប៉េជុយ ធីបសៃ** មិនធ្លាប់បានឃើញមុនពេលមានកិច្ចដំណើរការនីតិវិធីនេះឡើយ។ ដំបូងឡើយ លោកមេធាវី **ហ្សាស្តី ប៉ៅ** បានជំទាស់នឹងព្រះរាជអាជ្ញា **ខេល លីសាក់** ចំពោះការប្រើបទសម្ភាសន៍លើមូលដ្ឋានបច្ចេកទេស ដោយថ្លែងថា ការអនុវត្តន៍របស់តុលាការជាទូទៅ គឺត្រូវចាប់ផ្តើមដោយសួរសាក្សី ថាតើគាត់ធ្លាប់បានឃើញឯកសារនេះ ឬទេ ប្រសិនបើចម្លើយគឺ "ទេ" នោះឯកសារនឹងត្រូវតែដកចេញពីសាក្សី និងពីអេក្រង់កំព្យូទ័ររបស់ភាគីពាក់ព័ន្ធទាំងអស់ផងដែរ។ ព្រះរាជអាជ្ញា **លីសាក់** បានឆ្លើយតបថា ការលើកឡើងក្នុងការជំទាស់របស់មេធាវី **ហ្សាស្តី ប៉ៅ** គឺមិនត្រឹមត្រូវ ត្រង់ចំណុចដែលថា វាជាការអនុវត្តរបស់តុលាការ ផ្ទុយមកវិញគឺថា "មានកាលៈទេសៈជាច្រើន" ដែលតម្រូវឲ្យសាក្សីត្រូវ ពិនិត្យមើលលើឯកសារដែលគាត់មិនធ្លាប់ឃើញពីមុនមក ជាពិសេសចំពោះឯកសារដែលមានបទសម្ភាសន៍របស់សាក្សីយ៉ាងដូច្នេះ។ អង្គជំនុំជម្រះ បានចេញសេចក្តីសម្រេចប្រឆាំងនឹងការជំទាស់របស់លោក **ហ្សាស្តី ប៉ៅ**។

## គ. ការអនុវត្តចំពោះការប្រើប្រាស់ឯកសារបានពីបុគ្គលឯកជន ដែលបុគ្គលនោះបានស្ថិតក្នុងកាលវិភាគត្រូវមកផ្តល់សក្ខីកម្មនៅក្នុងបន្ទប់តុលាការ

ភ្លាមៗក្រោយពីការជំទាស់របស់មេធាវី **ហ្សាស្តី ប៉ៅ** ដូចបានរៀបរាប់ខាងលើ លោកមេធាវី **កាណាវ៉ាស** បានលើកឡើងនូវការជំទាស់មួយដែលខ្លឹមសាររបស់វា ត្រូវបានស្គាល់ថា បានលើកឡើងម្តងហើយម្តងទៀតនៅក្នុងប៉ុន្មានសប្តាហ៍ចុងក្រោយនេះ។ ដោយបានដឹងថា លោក **ហង់រី ឡូកា** គឺជាបុគ្គលបម្រុងមួយរូបដែលនឹងមកផ្តល់ភស្តុតាងក្នុងនាមជាសាក្សីចំពោះមុខអង្គជំនុំជម្រះ នៅពេលសមគួរណាមួយនោះ លោក **កាណាវ៉ាស** បានសួរថាតើតុលាការឥឡូវនេះគឺកំពុងស្ថិតក្នុងស្ថានភាពដូចគ្នានឹងករណីរបស់លោក **ហ្វីលីព ស្សត** ជាអ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រ បើនិយាយពីចំណុចនៅពេលភាគីចង់ប្រើឯកសារនានាដែលបានពីសាក្សី ខណៈដែលគាត់មិនទាន់ត្រូវបានផ្តល់សក្ខីកម្មចំពោះមុខតុលាការនៅឡើយ។ លោក **កាណាវ៉ាស** យល់ថា តុលាការកំពុងត្រឡប់ទៅរកការប្រើប្រាស់ឯកសាររបស់សាក្សីមួយរូប ដែលមិនទាន់បានចូលខ្លួនមកផ្តល់សក្ខីកម្ម និងថា ភាគីកំពុងតែប្រើឯកសាររបស់សាក្សីនោះ មកសួរផ្ទាញ់ចំពោះសាក្សីបច្ចុប្បន្នទៅវិញ។ ដើមឡើយ បញ្ហានេះត្រូវបានកើតឡើងក្នុងអំឡុងពេល "សវនាការលើឯកសារ" កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ហើយដែលក្នុងនោះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធមិនអនុញ្ញាត ឲ្យមេធាវីអន្តរជាតិការពារក្តីលោក **នួន ជា** គឺមេធាវី **អ៊ីយ៉ានូហ្ស៊ី** ដាក់បង្ហាញឯកសារដែលបានពីស្នាដៃនិពន្ធរបស់អ្នកជំនាញ លោក **ហ្វីលីព ស្សត** និងលោក **ស្ទីវហ្វិន ហេដឌឺរ** និង

បានធ្វើការណែនាំដល់មេធាវីថា គាត់ត្រូវរង់ចាំរហូតដល់មានការបង្ហាញខ្លួនរបស់អ្នកជំនាញទាំងនេះ នៅចំពោះមុខតុលាការក្នុងនាមជាសាក្សីអ្នកជំនាញសិន ហើយដល់ពេលនោះ ភាគីនៃសំណុំរឿងទាំងអស់ អាចនាំគ្នាសួរដេញដោលដើម្បីសុំការបញ្ជាក់នូវព័ត៌មានផ្សេងៗបាន។[23] សប្ដាហ៍មួយទៀតបន្ទាប់ពីការណែនាំនេះ អង្គជំនុំជម្រះបានគូសបញ្ជាក់នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ដោយបានថ្លែងដូចខាងក្រោមៈ

> *ការអាននូវសម្រង់ខ្លឹមសារណាមួយពីសៀវភៅ ឬស្នាដៃនិពន្ធរបស់បុគ្គលណាម្នាក់ ដែលត្រៀមនឹងមកបង្ហាញខ្លួននៅចំពោះមុខតុលាការ គឺមិនមែនជាការសមស្របនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមការពារក្ដីអាចនឹងប្រើប្រាស់នូវឯកសារណាមួយ ដោយធ្វើការដកស្រង់តែខ្លឹមសារដើម្បីយកមកចោទសួរទៅកាន់សាក្សី ប៉ុន្តែគួរចៀសវាងនូវការដកស្រង់សម្ដីទាំងស្រុងពីប្រភេទឯកសារដែលបាន និងកំពុងលើកឡើងនេះ ពោលគឺការដកស្រង់នូវការវិភាគនូវយោបល់ណាមួយពីអ្នកជំនាញ ដើម្បីធ្វើជាមូលដ្ឋានក្នុងការសួរដេញដោលទៅលើសាក្សី គឺមិនមែនជារឿងសមរម្យទេ ដោយហេតុថា ការវិភាគនោះមិនទាន់បានទទួលការឆ្លើយបញ្ជាក់ ឬបានពិភាក្សាជាមួយអ្នកវិភាគនៅឡើយ ។[24]*

ឆ្លើយតបទៅនឹងការជំទាស់របស់មេធាវី **កាណាវ៉ាស** ព្រះរាជអាជ្ញា **ខេល លីសាក់** បានបញ្ជាក់ថា លោកនឹងមិនសួរពីមតិ ឬ ការសង្កេតណាមួយរបស់លោក **ហង់រី ឡូកា** ឡើយ និងសួរតែអំពីសេចក្ដីថ្លែងការណ៍ដែលមានការជាប់ពាក់ព័ន្ធនឹងសាក្សីបច្ចុប្បន្ននេះតែប៉ុណ្ណោះ។ ព្រះរាជអាជ្ញា **ខេល លីសាក់** ក៏បានរម្លឹកពីសក្ខីកម្មរបស់សារក្សី **ភី ភួន**[25] ដែលនៅក្នុងគ្រានោះ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីសាកសួរសាក្សីរូបនេះ ដោយផ្អែកលើសេចក្ដីថ្លែងការណ៍របស់គាត់ បូករួមទាំងសេចក្ដីថ្លែងការណ៍នៅក្នុងសៀវភៅរបស់លោក **ហ្វីលីព ស្សត** ផងដែរ។ ទីបំផុត លោកប្រធាន **និល ណុន** បានសម្រេចថា ការជំទាស់របស់ភាគីការពារក្ដី គឺមិនត្រឹមត្រូវទេ ដោយសារឯកសាររបស់លោក **ហង់រី ឡូកា** បានដកស្រង់នូវចម្លើយរបស់សាក្សី **ប៉េជុយ ជីបសែ** ផ្ទាល់នៅក្នុងការធ្វើសម្ភាសន៍។ ដូច្នេះ ភាគីទាំងឡាយអាចនឹងត្រូវបានអនុញ្ញាតឲ្យប្រើឯកសារបៀបនេះបាន ដើម្បីធ្វើការសួរដេញដោលលើសាក្សី។

## ឃ. ភាពជឿទុកចិត្តនៃបទសម្ភាសន៍របស់សាក្សីជាមួយបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេត

នៅព្រឹកថ្ងៃពុធ លោកមេធាវី **ហ្សាស្ទី ប៉ៅ** បានចោទសួរអំពីភាពជឿជាក់បាននៃបទសម្ភាសន៍រវាងសាក្សី **ប៉េជុយ ជីបសែ** ដែលបានធ្វើជាមួយមន្ត្រីផ្នែកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ យោងតាមលោកមេធាវី និងក្រុមការងារដែលជាជនជាតិខ្មែររបស់ខ្លួន បានឲ្យដឹងថា តាមរយៈខ្សែអាត់សំឡេងនៅពេលមន្ត្រីស៊ើបអង្កេតកំពុងសួរសំណួរទៅកាន់សាក្សី គេអាចស្ដាប់ឮបានថា មានការណែនាំឲ្យសាក្សីពិនិត្យមើលលើកំណត់ហេតុនៅក្នុងសៀវភៅកត់ត្រាមួយ ឬ កំណត់ត្រាចំណាំអ្វីមួយ ដែលបន្ទាប់ពីសាក្សីបានធ្វើតាមមក សាក្សីបានផ្ដល់ចម្លើយផ្សេងខុសពីចម្លើយដើមរបស់គាត់។ នៅពេលដែលត្រូវបានសាកសួរថា តើសាក្សីមានបានអាននូវ

កំណត់ហេតុ ឬកំណត់ត្រាដែលរៀបចំដោយអ្នកដទៃ និងមិនមែនជារបស់លោកទេ ក្នុងពេលផ្តល់ចម្លើយដល់ចៅក្រមស៊ើបអង្កេត? សាក្សីបានថ្លែងថា “ខ្ញុំបានអានយ៉ាងយកចិត្តទុកដាក់ នៅពេលមន្ត្រីស៊ើបអង្កេតគាត់ប្រគល់ដល់ដៃខ្ញុំ...”។

អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសំណើរបស់លោកមេធាវី **ប៉ៅ** ដែលបានស្នើសុំឲ្យចាក់សំឡេងខ្សែអាត់នៃការសម្ភាសន៍នៅក្នុងបន្ទប់សវនាការសាធារណៈ បើទោះបីជាមានការជំទាស់ពីសហព្រះរាជអាជ្ញាអន្តរជាតិ លោក **ឌេល លីសាក់** ដែលបានតវ៉ាថា មេធាវី **ប៉ៅ** គួរតែប្រើ ពេលវេលាដើម្បីរៀបចំនូវប្រតិចារឹកចេញពីខ្សែអាត់សំឡេងនេះជាមុនសិន ជាជាងការដែលគ្រាន់តែបង្ហាញប្រាប់ភាគីពីលេខកូដនៃខ្សែអាត់ ឬក៏គ្រាន់តែប្រាប់ពីម៉ោងពេលរបស់ខ្សែអាត់ ចាប់ពីនាទីណាដល់នាទីណាដូច្នេះ។ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសហភាតាជាក្រុមមេធាវីការពារក្តីរបស់លោក **ខៀវ សំផន** ដែលបានយល់ដូចគ្នាថា ការពិតសាក្សីបានស្នើសុំមើលសៀវភៅកំណត់ត្រារបស់គាត់សិនមុនឆ្លើយសំណួរ លោកមេធាវី **ប៉ៅ** ក៏បានស្នើសុំចាក់ខ្សែអាត់សំឡេងម្តងទៀត ដោយសុំឲ្យមានការបកប្រែពីអ្នកបកប្រែរបស់តុលាការក្នុងផ្នែកនៃខ្សែអាត់ដែលគាត់នឹងចាក់ ជាពិសេសឲ្យបកប្រែក្នុងចំណុចមួយ “ឲ្យខ្ញុំសុំមើលសៀវភៅកំណត់ត្រា” បន្តិចបាទ។ គួរកត់ សម្គាល់ថា យោងតាមប្រតិចារិតនៃការបកប្រែរបស់តុលាការ ហាក់ដូចជាមានការភ័ន្តច្រឡំ រវាងខ្លឹមសារដែលបានដកស្រង់ ជាពិសេសពាក្យ “នោម” និង “ណូត”។ ក្នុងប្រតិចារិតនៃការបកប្រែគឺ “សុំលោកចេញទៅនោមបន្តិចបាទ”។

ទោះជាយ៉ាងណាក្តី ព្រះរាជអាជ្ញា លោក **ឌេល លីសាក់** បានជំទាស់ទៅនឹងការធ្វើសេចក្តីថ្លែងការណ៍ដកស្រង់ខុសរបស់មេធាវី **ប៉ៅ** ជាមួយនឹងការតវ៉ាថា សហភាតាខ្មែររបស់លោក មិនអាចស្តាប់យល់បានឡើយ ថាតើបុគ្គលណាមួយជាអ្នកនិយាយនៅក្នុងខ្សែអាត់នោះ។ ចំណុចនេះ លោកប្រធានតុលាការ ចៅក្រម **និល ណុន** បានសួរទៅកាន់សាក្សីដោយផ្ទាល់ថា តើគាត់ទទួលស្គាល់ទេ ថាសំឡេងនៅក្នុងខ្សែអាត់គឺជាសំឡេងរបស់លោក? សាក្សីបានថ្លែងថា គាត់ដូចជាមិនប្រាកដទេ “ដូចជាមិនមែនសំឡេងរបស់ខ្ញុំ...ស្តាប់មិនច្បាស់”។ បន្ទាប់ពីបានសួរសំណួរដើម្បីសុំការបញ្ជាក់ជាបន្តពីសាក្សីរួចមក ទីបំផុតប្រធានតុលាការបានថ្លែង ខ្លួនគាត់ផ្ទាល់ក៏យល់ឃើញថាមានភាពមិនច្បាស់លាស់នៅក្នុងខ្សែអាត់មួយនេះ “យើងក៏ស្តាប់មិនច្បាស់ដែរ” និងយល់ថា ពាក្យ “ណូត” ដែលបានប្រើនៅក្នុងខ្សែអាត់ ផ្អែកតាមការលើកឡើងរបស់មេធាវី **ប៉ៅ** ហាក់ដូចជាមិនត្រឹមត្រូវទេ ព្រោះអ្វីដែលលោកចៅក្រមបានឮ គឺសំឡេងនៅក្នុងខ្សែអាត់បាននិយាយថា “សុំទៅបន្ទប់ទឹក ឬទៅនោម” មិនមែនសុំមើលសៀវភៅ “ណូតប៊ុក” ទេ។

តពីនេះ លោកប្រធានតុលាការ បានណែនាំឲ្យមេធាវី **ប៉ៅ** បន្តសួរដេញដោលនូវសំណួរថ្មីដល់សាក្សី។ មេធាវី **ប៉ៅ** នៅតែមានះ ដោយបានស្នើទៅប្រធានតុលាការ ដើម្បីចាក់ខ្សែអាត់សំឡេងដដែល តែក្នុងផ្នែកផ្សេង និងវែងជាងមុន ដើម្បីផ្ទៀងផ្ទាត់ថាតើសំឡេងនៅក្នុងខ្សែអាត់នេះ ជាសំឡេងសាក្សីមែន ឬមិនមែន។ លើសពីនេះទៀត ជាការឆ្លើយតបទៅនឹងការស្មានពីខាងដើមរបស់លោកប្រធានចៅក្រមដែលថា សាក្សីមិនមែនសុំមើល

សៀវភៅ “ណូតប៊ុក” ទេ តែបានសុំ “ទៅនោម” មេធាវីបានតវ៉ាថា “វាមិនសមទំនងទេ” ដែលលោកប្រធានតុលាការអះអាងថា សាក្សីសុំទៅ “នោម” ពីព្រោះ បើសិនជាដូច្នេះមែន ហេតុអ្វីបានជាមន្ត្រីស៊ើបអង្កេតនៅតែបន្តសំណួរភ្លាមៗ ជាជាងការ អនុញ្ញាតឲ្យសាក្សីទៅនោមសិន។

ជាថ្មីម្តងទៀត ព្រះរាជអាជ្ញា **ខេល លីសាក់** បានជំទាស់ទៅនឹងការដកស្រង់សេចក្តីថ្លែងការណ៍សាក្សីខុសរបស់មេធាវី **ប៉ៅ** ដោយបានស្នើឲ្យមេធាវីរូបនេះឲ្យ “ឈប់ធ្វើពើ” ដែលថាគ្រប់គ្នានៅក្នុងបន្ទប់សវនាការឮចេញពីខ្សែអាត់ថា “ណូតប៊ុក”។ ទោះជាយ៉ាងណាក្តី ព្រះរាជអាជ្ញាមិនបានបដិសេធនឹងមេធាវី **ប៉ៅ** ទេ ដែលបានស្នើសុំចាក់ខ្សែអាត់សំឡេងម្តងទៀត។ បន្ទាប់ពីការ ពិភាក្សាជាច្រើនលើកក្នុងចំណោមចៅក្រមនៃអង្គជំនុំជម្រះ លោកស្រីចៅក្រម **ស៊ីលវៀ ខាតវ៉ាយថ៍** បាននិយាយក្នុងនាមអង្គជំនុំជម្រះសាលាដំបូង ដោយបានកំណត់ដូច្នេះថា មិនចាំបាច់ចាក់ខ្សែអាត់សំឡេងម្តងទៀតទេ ដោយសារតែពាក្យពេចន៍ដែលបានរៀបរាប់នៅក្នុងខ្សែអាត់នោះ គឺឮមិនច្បាស់ និងក៏មិនអាចសន្និដ្ឋានថានរណាជាអ្នកនិយាយឡើយ។ ជាការឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ មេធាវី **ប៉ៅ** បានដាក់សំណើបន្ថែមទៀតក្នុងចេតនាផ្សេងគ្នា ដែលទង្វើនេះ ធ្វើឲ្យគាត់ទទួលរងនូវការព្រមានពីលោកស្រីចៅក្រម **ខាតវ៉ាយថ៍** ដូច្នេះថា មេធាវីមិនចាំបាច់លើកឡើងនូវសំណើរបស់ខ្លួនដោយពាក្យពេចន៍ផ្សេងនោះទេ ព្រោះវាមិនខុសគ្នានឹងគោលការណ៍ដដែល ដែលគាត់បានស្នើកន្លងទៅនោះឡើយ។

សុចរិតភាពនៃការិយាល័យសហចៅក្រមស៊ើបអង្កេត បានស្ថិតនៅក្រោមការពិនិត្យពិច័យ ម្តងហើយម្តងទៀតនៅក្នុងអំពីរបៀបរបបធ្វើការពីអតីតកាលរបស់អង្គភាពនេះ។ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចដូចគ្នា ដោយសន្មតសន្និដ្ឋាននូវសុចរិតភាពនៃការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ ឆ្លើយតបទៅនឹងសំណើមួយ ធ្វើឡើងដោយលោក **កាណាវាស** កាលពីខែកញ្ញាកន្លងទៅ នៅពេលដែលមេធាវីរូបនេះ បានស្នើសុំចាក់ខ្សែអាត់សំឡេងរបស់សាក្សីម្នាក់ក្នុងពេលដែលសាក្សីនោះ កំពុងផ្តល់ចម្លើយឲ្យមន្ត្រីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ប៉ុន្តែ អង្គជំនុំជម្រះមិនបានអនុញ្ញាតឲ្យមានការចាក់ខ្សែអាត់សំឡេងនោះ សារថ្មីទេ ក្រោមហេតុផលថា ភាគីគួរតែលើកឡើងពីសំណួរទាំងឡាយរបស់គេ ដែលទាក់ទងនឹងវិធីសាស្ត្រធ្វើការរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត តែអំឡុងពេលដំណាក់កាលនៃស៊ើបអង្កេតនៃសំណុំរឿងនេះតែប៉ុណ្ណោះ។ លោកស្រីចៅក្រម **ស៊ីលវៀ ខាតវ៉ាយថ៍** បាននិយាយក្នុងនាមអង្គជំនុំជម្រះ ដោយបានផ្តល់នូវសេចក្តីសម្រេចដូចខាងក្រោមៈ

> *ដូច្នេះ វិធានទូទៅគឺថា មានការសន្មតទុកជាមុនផ្អែកច្បាប់អំពីសុចរិតភាពនៃការស៊ើបអង្កេត ដែលកង្វល់ណាមួយស្តីពីវិធីសាស្ត្រ ឬក៏ប្រធានបទនេះ បានឆ្លងកាត់ក្នុងអំឡុងធ្វើការស៊ើបអង្កេត ត្រូវតែត្រូវបានលើកឡើងក្នុងអំឡុងពេលស៊ើបអង្កេត... ភាគីអាចនឹងឆ្លើយបដិសេធបបានក្នុងពេលនោះ លើកលែងតែនៅក្នុងករណីពិសេសតែប៉ុណ្ណោះ ។ ការឆ្លើយបដិសេធបែបនេះ មិនត្រូវឲ្យទាក់ទងនឹងបញ្ហាបច្ចេកទេសនោះទេ ប៉ុន្តែជាខ្លឹមសារជាក់ស្តែងចេញពីបទបង្ហាញ ហើយចំពោះការលើកយក ករណីលើកលែងណាមួយមេធាវី ឬភាគីត្រូវតែបំពេញចិត្តអង្គជំនុំ*

*ជម្រះសាលាដំបូង ដោយលើកយកមូលដ្ឋានច្បាស់លាស់ស្តីពីភាពអាចទុកចិត្តបាន នៃផ្នែកណាមួយនៃភាពមិនប្រក្រតីពីការស៊ើបអង្កេតនោះ។[26] (រាល់ភស្តុតាងដែលបានពីការស៊ើប អង្កេត ជាទូទៅបានទទួលស្គាល់រួចហើយ ប៉ុន្តែវាអាស្រ័យទៅលើចៅក្រមជាអ្នកផ្តល់ តម្លៃឲ្យវា ដូច្នេះភាគីគួរជំទាស់តែលើអ្វីដែលពាក់ព័ន្ធនឹងភស្តុតាងដែលបានដាក់ បង្ហាញដោយផ្ទាល់នេះ តែមិនមែនពីរបៀបនៃការបង្ហាញឡើយ)។*

គួរឲ្យចាប់អារម្មណ៍ នៅពេលក្រោយមកទៀតនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យលោក **ប៉ៅ** ចាក់ខ្សែអាត់សំឡេងដែលដកស្រង់ចេញពីការសម្ភាសន៍របស់មន្ត្រី ផ្នែកស៊ើបអង្កេតជាថ្មីម្តងទៀត ដើម្បីវាយតម្លៃដឹងបានថា តើសាក្សីបានរងសម្ពាធពីបុគ្គលម្នាក់ ឈ្មោះ **តា ឈុន** ដែលបានហាមសាក្សីមិនឲ្យផ្តល់ព័ត៌មានលម្អិតជាក់លាក់ទៅកាន់លោក **អង់រី ឡូកា**។[27]

## ង. វត្តមានរបស់លោក អង់រី ឡូកា ក្នុងសាលសវនាការសម្រាប់សាធារណជន

នៅក្នុងវគ្គបញ្ចប់នៃសវនាការកាលពីថ្ងៃចន្ទ លោក **កាណាវ៉ាស** បានចង្អុលបង្ហាញថាលោក **អង់រី ឡូកា** ជាបុគ្គលដែលបានធ្វើសម្ភាសជាមួយនឹងសាក្សី **ប៉េជុយ ជីបសែ** បានអង្គុយតាមដានសវនាកានៅក្នុងសាលសាធារណជន ដែលវត្តមាននេះ ត្រូវបានមេធាវីយល់ថា វាជាមធ្យោបាយយ៉ាងទូលំទូលាយមួយ ក្នុងការត្រួតពិនិត្យមើលការនិយាយរបស់សាក្សី ឬអាចនិយាយបានថា អាចជះឥទ្ធិពលដល់សាក្សីក្នុងការផ្តល់សក្ខីកម្ម។ លោកមេធាវីបានអធិប្បាយពីភាពជួនគ្នា ដែលលោក **ហង់រី ឡូកា** សម្រេចចិត្តមកតាមដានសវនាការនៅពេលសាក្សី **ប៉េជុយ ជីបសែ** ជាបុគ្គល ដែលគាត់ធ្លាប់សម្ភាសន៍ពីមុន ត្រូវចូលខ្លួនមកផ្តល់សក្ខីកម្ម ។ ដោយសារតែរាល់ឈ្មោះរបស់សាក្សី ដែលមុននឹងត្រូវមកផ្តល់សក្ខីកម្មត្រូវបានទុកជាជាការសម្ងាត់ មេធាវីការពារក្តីរបស់លោក **អៀង សារី** បានស្នើថា អង្គជំនុំជម្រះគួរធ្វើការស៊ើបអង្កេត ថាតើព័ត៌មាននៃកាលវិភាគស្តាប់សក្ខីកម្មរបស់សាក្សី **ប៉េជុយ ជីបសែ** ត្រូវបានបែកធ្លាយទៅក្រៅដោយភាគីណាមួយនៃសំណុំរឿង។ ព្រះរាជអាជ្ញា **ឌេល លីសាក់** បានក្រោកឈរយ៉ាងរហ័ស ដោយបានធានាចំពោះអង្គជំនុំជម្រះថា ភាគីសហព្រះរាជអាជ្ញា មិនបានទាក់ទងជាមួយលោក **ហង់រី ឡូកា** ទេ ចំណែកឯការជ្រើសរើសប្រើប្រាស់នូវបទសម្ភាសន៍ដែលធ្វើឡើងរវាងបុគ្គលនេះនឹងលោក **ប៉េជុយ ជីបសែ** គឺបានមកពីលទ្ធផលនៃការស្រាវជ្រាវកាលពីសប្តាហ៍មុនតែប៉ុណ្ណោះ ដើម្បីត្រៀមខ្លួនសម្រាប់សវនាការនៅសប្តាហ៍នេះ។ អង្គជំនុំជម្រះសាលាដំបូង មិនបានផ្តល់មតិយោបល់អ្វីចំពោះបញ្ហានេះឡើយ។

## ច. សក្ខីកម្មក្រៅពីវិសាលភាពនៃសំណុំរឿង០០២/០១

មេធាវី **ហ្សាស្គី ប៉ៅ** បានជំទាស់ទៅនឹងសំណួររបស់ព្រះរាជអាជ្ញាជាតិ លោក **សេង ប៊ុនឃាង** ដែលបានសួរទៅកាន់សាក្សី **ប៉េជុយ ជីបសែ** ស្តីពីការជម្លៀសពលរដ្ឋចេញពីខេត្តសៀមរាប ក្រោមហេតុផលថា ការជម្លៀស

មិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១។ ក្នុងការការពារសហភាតាជាតិរបស់ខ្លួន លោក **ខេល លី សាក់** បានថ្លែងតបថា សំណួរគឺដើម្បីជំរុញឲ្យកាន់តែឃើញពីភាពពាក់ព័ន្ធទៅនឹងការកំណត់គោលនយោបាយ និងការអនុវត្តផែនការជម្លៀសរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយវាក៏ជាបន្ទុកនៃការបង្ហាញភស្តុតាងដើម្បីបញ្ជាក់ថា មានចលនាជម្លៀសប្រជាជននៅទូទាំងប្រទេសត្រូវបានធ្វើក្នុងលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធ ដែលជាធាតុពីរចែងនៅក្នុងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ព្រះរាជអាជ្ញាបានរម្លឹកដល់អង្គជំនុំជម្រះថា កាលពីមុន អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមានការសួរសំណួរទាក់ទងនឹងការជម្លៀសចេញនៅ តាមមណ្ឌលទីក្រុងនានា ដោយផ្អែកលើហេតុផលដូចគ្នានេះ។ ប្រធានតុលាការបានសម្រេច ប្រឆាំងនឹងការជំទាស់ ដោយបានថ្លែងបញ្ជាក់ថា សាក្សីត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មជូនតុលាការនូវចំណេះដឹង ឬការដឹងឮរបស់គាត់ដោយផ្ទាល់ ស្តីពីគោលនយោបាយទូទៅរបស់ខ្មែរក្រហមចំពោះការជម្លៀស។

ខណៈពេលដែលមន្ទីរសន្តិសុខពង្រ ត្រូវបានលើកយកមកពិភាក្សាយ៉ាងទូលំទូលាយក្នុង អំឡុងសក្ខីកម្មរបស់សាក្សី **ប៉េជុយ ជីបសែ** អង្គជំនុំជម្រះបានមានប្រតិកម្មក្នុងអំឡុងពេលដែលមេធាវីតំណាងដើមបណ្តឹងកញ្ញា **នូស៊ីន សាកាវ៉ាទី** ធ្វើការសួរដេញដោលទៅកាន់សាក្សីរូបនេះ ត្រង់ចំណុចដែលកញ្ញាបានព្យាយាមឲ្យមានការផ្តល់ព័ត៌មានលម្អិត ស្តីពីការធ្វើទុក្ខបុកម្នេញទៅលើអ្នកទោស។ ប្រធានតុលាការ លោកចៅក្រម **និល ណុន** បានរម្លឹកមេធាវីថា សាក្សីត្រូវបានកោះហៅឲ្យមកឆ្លើយបំភ្លឺ ស្តីពីការអនុវត្តគោលនយោបាយជម្លៀសដំណាក់កាលដំបូង និងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋាន រីឯបញ្ហាមន្ទីរសន្តិសុខ គឺមិនស្ថិតនៅក្នុងដែនវិសាលភាពនៃការជំនុំជម្រះក្តី បច្ចុប្បន្ននេះទេ។ ការលើកឡើងនេះ ហាក់ដូចជាបង្ហាញឲ្យឃើញថា ការជជែកពិភាក្សាអំពី មន្ទីរសន្តិសុខពង្រ គឺអាចអនុញ្ញាតឲ្យធ្វើទៅបាន លុះត្រាតែវាទាក់ទងទៅនឹងបញ្ហាជាក់លាក់ ដូចទើបតែបានរៀបរាប់ខាងលើនេះ។

## ផ្នែកទី៤៖ ការគ្រប់គ្រងសវនាការ

ជារួម ដំណើរការនីតិវិធីសប្តាហ៍នេះ បានប្រព្រឹត្តទៅយ៉ាងល្អជាមួយនឹងការគ្រប់គ្រងពេលវេលាដ៏មានប្រសិទ្ធភាព។ សហជនជាប់ចោទបានចូលរួមតាមដានក្នុងដំណើរការនីតិវិធីទាំងនៅក្នុងបន្ទប់សវនាការ ឬ ពីបន្ទប់ឃុំខ្លួននៅខាងក្រោម ដែលមានភ្ជាប់ទៅដោយប្រព័ន្ធសោតទស្សន៍ លើកលែងតែករណីរបស់ជនជាប់ចោទ **អៀង សារី** កាលពីថ្ងៃពុធ។ បញ្ហានៃការគ្រប់គ្រងសវនាការ ក៏ត្រូវបានកើតឡើង នៅពេលដែលប្រធានតុលាការ លោកចៅក្រម **និល ណុន** ហាក់ដូចជាយល់ខុសនូវការធ្វើសំណើរបស់មេធាវី **ប៉ៅ** ដែលបានដាក់ជូនដល់អង្គជំនុំជម្រះ។

### ក. វត្តមាន

យោងសារតែមានការព្រួយបារម្ភពីបញ្ហាសុខភាពរបស់លោក **អៀង សារី**[28] និងលោក **នួន ជា**[29] ជនជាប់ចោទទាំងពីរត្រូវបានអវត្តមាន ពីក្នុងបន្ទប់សវនាការពេញមួយសប្តាហ៍នេះ។ លោក **ខៀវ សំផន** បានតាមដានកិច្ច

ដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនរបស់លោក កាលពីថ្ងៃចន្ទ ដោយសារតែបញ្ហាសុខភាព ប៉ុន្តែបានមានវត្តមាននៅក្នុងបន្ទប់សវនាការពេញមួយថ្ងៃពុធ។

**វត្តមានរបស់ភាគី៖** ភាគីទាំងអស់បានបង្ហាញខ្លួនជាប្រក្រតីក្នុងអំឡុងពេលសប្តាហ៍នេះ។ ទោះជាយ៉ាងនេះក្តី បើតាមការសង្កេតពីអ្នកសង្កេតការណ៍បានឲ្យដឹងថា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក **ពេជ្រ អង្គ** បានអវត្តមានក្នុងអំឡុងសវនាការវគ្គចុងក្រោយ (វគ្គទី៤) កាលពីថ្ងៃពុធ។ សប្តាហ៍នេះ លោក **ខៀវ សំផន** ត្រូវបានតំណាងដោយមេធាវីអន្តរជាតិការពារក្តីរបស់គាត់ គឺលោកស្រី **អាន់តា ហ្គីសសេ** រួមជាមួយសហភាតាជាតិរបស់លោកស្រី គឺលោកមេធាវី **គង់ សំអុន**។

**ការចូលរួមពីសាធារណជន៖** កាលពីព្រឹកថ្ងៃចន្ទ មានប្រជាជនប្រមាណជា ៣០០នាក់ មកពីខេត្តកំពង់ចាម បូករួមនឹងភ្ញៀវអន្តរជាតិប្រមាណជា២០នាក់ផ្សេងទៀត បានចូលរួមតាមដានសវនាការ។ នាពេលរសៀលថ្ងៃដដែលនេះ មានសិស្សានុសិស្សផ្នែកមេកានិចនៃអង្គការដើម្បីភាពញញឹមនៃកុមារ (Pour un Souire d'Enfant) បានចូលរួមតាមដានសវនាការនៅសាលសាធារណជន។ ដោយឡែកនៅព្រឹកថ្ងៃពុធវិញ មានប្រជាជនប្រមាណជា ២០០នាក់ បូករួមទាំងភ្ញៀវអន្តរជាតិប្រមាណជា ៣០នាក់ផ្សេងទៀត បានអង្គុយតាមដានដំណើរការនីតិវិធីសវនាការពីសាលសាធារណជន។ មានប្រជាជនប្រមាណជា ១០០នាក់ មកពីខេត្តកំពង់ចាម រួមទាំងភ្ញៀវអន្តរជាតិ ០៥រូប ផ្សេងទៀត បានចូលរួមតាមដានសវនាការនៅពេលរសៀលថ្ងៃដដែលនេះ។

## ខ. ការគ្រប់គ្រងរបស់តុលាការ

កាលពីថ្ងៃចន្ទ ប្រធានតុលាការ លោកចៅក្រម **និល ណុន** ហាក់ដូចជាភ័ន្តច្រឡំ ដោយសារបែបបទនៃការស្នើរបស់មេធាវី **ហ្សាស្លី ប៉ៅ** ដែលបានសុំឲ្យរក្សាទុកមួយអន្លើ នូវកំណត់ត្រាបទសម្ភាសន៍របស់សាក្សី **ប៉េជុយ ដឹបសៃ** ដែលបានធ្វើជាមួយលោក **អង់រី ឡូកា** បើសាក្សីមិនទាន់ផ្តល់សក្ខីកម្មទេនោះ។[30] លោកមេធាវី **ប៉ៅ** បានស្នើជាយោបល់ថា វិធានការបែបនេះ នឹងជួយទប់ស្កាត់សាក្សីមិនឲ្យអានឯកសារកំណត់ត្រាជាមុន ដែលទង្វើនេះអាចជាហានិភ័យមួយដែលអាចបំពុលដល់សក្ខីកម្មរបស់គាត់បាន។ សំណើនេះមិនត្រូវបានដោះស្រាយទេ ហើយនៅពេលដែលលោក **ប៉ៅ** បានក្រើនរម្លឹកតុលាការដើម្បីឲ្យចេញសេចក្តីសម្រេចលើបញ្ហានេះ ប្រធានតុលាការបានថ្លែងថា សំណើនេះនឹងត្រូវសម្រេចនៅលើនៅព្រឹកថ្ងៃពុធ និងបានប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃចន្ទភ្លាម។ អ្នកឃ្លាំមើលសវនាការ បានសង្កេតឃើញថា លោកស្រីចៅក្រម **ស៊ីលវៀ ខាតវ៉ាយថ៍** បានសម្តែងកាយវិការ (ឈ្ងោកខ្សិប និង យកដៃវាទៅកាន់លោកចៅក្រម **និល ណុន**) ហាក់ដូចជា ធ្វើអន្តរាគមន៍ក្នុងការចេញសេចក្តីសម្រេចនោះទេ ប៉ុន្តែកិច្ចដំណើរការនីតិវិធីថ្ងៃនេះ ត្រូវបានបញ្ចប់រួចទៅហើយ។

## គ. ការគ្រប់គ្រងពេលវេលា

អង្គជំនុំជម្រះបានខិតខំព្យាយាមតាមដែលអាចធ្វើទៅបាន ដើម្បីចាត់ចែងឲ្យមានសវនាការនីតិវិធីចំនួនពីរថ្ងៃនៅសប្តាហ៍នេះ។ ទោះជាយ៉ាងនេះក្តី បញ្ហានៃការបែងចែកពេលវេលាឲ្យស្មើគ្នាដល់ភាគី ត្រូវបានលើកឡើង

ជាបញ្ហា។ ទាំងមេធាវីអន្តរជាតិការពារក្តីលោក **នួន ជា** គឺមេធាវី **ហ្សាស្គី ប៉ៅ** និងមេធាវីអន្តរជាតិការពារក្តីឲ្យលោក **ខៀវ សំផន** គឺលោកស្រី **អាន់តា ហ្គីសសេ** សុទ្ធតែបានធ្វើការតវ៉ាចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ខណៈដែលប្រធានតុលាការបានក្រើនរម្លឹក មេធាវី **ប៉ៅ** នៅពាក់កណ្តាលទីនៃការសួរដេញដោលរបស់គាត់ថា ពេលវេលាដែលអង្គជំនុំជម្រះ បានបម្រុងទុកសម្រាប់ក្រុមមេធាវីការពារក្តីទាំងបីក្រុមគឺជិតអស់ហើយ។ បើទោះបីជាក្រុមមេធាវីការពារក្តីរបស់លោក **ខៀវ សំផន** មិនមានបំណងនឹងសួរដេញដោលទៅលើសាក្សី **ប៉េជុយ ជីបសៃ** ក្តី ក៏លោកស្រី **អាន់តា ហ្គីសសេ** បានចង្អុលបង្ហាញថា អង្គជំនុំជម្រះបានផ្តល់ពេលវេលាបន្ថែម ដល់ភាគីសហព្រះរាជអាជ្ញា និងក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ ជាការគួរ ដែលអង្គជំនុំជម្រះ ក៏ត្រូវតែផ្តល់ពេលវេលាបន្ថែមឲ្យក្រុមការពារក្តីដូចគ្នា។ ជាការឆ្លើយតប លោកប្រធានតុលាការ បានមានប្រសាសន៍ថា ការបែងចែកពេលវេលា គឺមិនមែនជាបញ្ហាដាច់ខាតនោះទេ ហើយការផ្តល់ពេលវេលាបន្ថែម គឺអាស្រ័យទៅលើការគិតគូពិចារណាមួយចំនួន តួយ៉ាង ថាតើភាគីណាមួយបានប្រើប្រាស់ពេលវេលាក្នុងការសួរដេញដោលរបស់ខ្លួន មានភាពពាក់ព័ន្ធ និង មិនមែនច្រំដែល។ នៅចុងបញ្ចប់នៃការសួរដេញដោលរបស់គាត់ មេធាវី **ហ្សាស្គី ប៉ៅ** ជាថ្មីម្តងទៀតបានស្នើសុំអង្គជំនុំជម្រះ ធានាឲ្យបាននូវការយកចិត្តទុកដាក់ផ្តល់យុត្តិធម៌ដូចៗគ្នាសម្រាប់ភាគីទាំងអស់នៃសំណុំរឿង ជាពិសេសចំពោះការពិចារណាផ្តល់ម៉ោងបន្ថែមទៅឲ្យភាគីសហព្រះរាជអាជ្ញា ក៏ដូចជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏អាចធ្វើបានដូចគ្នា ប្រសិនបើក្រុមមេធាវីការពារក្តីរបស់លោក **អៀង សារី** ក៏ត្រូវការពេលវេលាបន្ថែមដែរនោះ។ ចៅក្រម **ខាត់រ៉ាយថ៍** បានស្តីប្រដៅមេធាវី **ប៉ៅ** និងថែមទាំងបានស្នើសុំឲ្យមេធាវីបញ្ឈប់ការខ្ជះខ្ជាយពេលវេលារបស់តុលាការ ដោយគ្រាន់តែលើកជជែកនូវ "បញ្ហាកំប៉ិកកំប៉ុក" ដូចនេះ។ លោកស្រីបានរម្លឹកមេធាវីថា លោកប្រធានអង្គជំនុំជម្រះ បានចេញសេចក្តីសម្រេចលើបញ្ហានេះរួចហើយ ហើយថា អង្គជំនុំជម្រះបានយកចិត្តទុកដាក់ស្មើៗគ្នាគ្រប់ភាគីទាំងអស់។

## ឃ. បញ្ហានៃការបកប្រែ និងបញ្ហាបច្ចេកទេស

មានបញ្ហាបច្ចេកទេស និងការបកប្រែតូចតាចតែប៉ុណ្ណោះដែលបានកើតឡើងសម្រាប់សប្តាហ៍នេះ។ ជាក់ស្តែង កាលពីថ្ងៃចន្ទ មានការបកប្រែខុសនូវកាលបរិច្ឆេទ ត្រង់ចំណុចដែលថា ការដួលរលំនៃទីក្រុងភ្នំពេញត្រូវបានបកប្រែថា បានកើតឡើងនៅក្នុងឆ្នាំ "១៩៧៩" មិនមែន "១៩៧៥" ទេ។ ទោះជាយ៉ាងក៏ដោយ ការបកប្រែច្រឡំនេះ ត្រូវបានកែតម្រូវនៅក្នុងអំឡុងពេលដំណើរការនីតិវិធីភ្លាមៗដែរ។

## ង.	តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃចន្ទ ០៦/០៨/១២ | ៩:០៤ | ១០:៣២-១០:៥២ | ១២:០២-១៣:៣១ | ១៤:៤២-១៥:០២ | ១៦:០៥ | ៤ ម៉ និង ៥២នាទី |
| ថ្ងៃពុធ ០៨/០៨/១២ | ៩:០០ | ១០:៣១-១០:៥៣ | ១២:០៨-១៣:៣១ | ១៤:៤១-១៥:០១ | ១៥:៥៨ | ៤ ម៉ និង ៥៣នាទី |
| *រយៈពេលសវនាការជាមធ្យម* | | | | *៥ ម៉ោង និង ០២ នាទី* | | |
| *រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ* | | | | *១០ ម៉ោង និង ០៥ នាទី* | | |
| *ចំនួនម៉ោង ថ្ងៃ និង សប្តាហ៍នៃសវនាការ* | | | | *៥៦៥ ម៉ោង និង ១១ នាទី* | | |
| *រយៈពេលសវនាការចំនួន ១២៨ ថ្ងៃ អំឡុងពេល ៣៩ សប្តាហ៍* | | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan (Case No. 002/19-09-2007-ECCC) before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok. This issue of KRT TRIAL MONITOR was authored by Mary Kristerie A. Baleva, Faith Suzzette Delos Reyes, Pavithra Prakash Nair, Noyel Ry, Sovanna Sek, and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org >, and at the websites of the East-West Center and the War Crimes Studies Center.

[1] Trial Chamber. Transcript of Trial Proceedings. (14 November 2013). E144.1 [hereinafter 14 NOVEMBER TRANSCRIPT].Lines 2-6. 95.

[2] KRT Monitor wrote a separate report on this hearing. See CASE 002 KRT TRIAL MONITOR. "Special Report: Ieng Thirith's Fitness to Stand Trial" (December 2012).

[3] CASE 002 KRT TRIAL MONITOR, Issue 42. Hearing on Evidence Week 39. (8-10 October 2012). [hereinafter ISSUE 42].

[4] Pe Chuy Chip Se was examined in the following order: National Prosecutor Seng Bunkheang; International Prosecutor Dale Lysak; National Civil Party Lawyer Ven Pov; International Civil Party Lawyer Nushin Sarkarati; International Judge Jean-Marc Lavergne; National Co-Lawyer for Nuon Chea Son Arun; International Co-Lawyer for Nuon Chea Jasper Pauw; National Co-Lawyer for Khieu Samphan Ang Udom.

[5] Henri Locard is an academic on Cambodia. Interntional Prosecutor Dale Lysak mentioned that he interviewed the Witness in 1991.

[6] Pongro Security Office was interchangeably referred to as Security Center and Security Office by the Witness and Parties during this testimony.

[7] Ang Udom presented the name in writing to the Witness and asked him whether he knew the person but not to state the name outloud. The prospective Witness was identified as a person who also worked at Pongro Security Office. The Witness confirmed he knew the person.

[8] 14 NOVEMBER TRANSCRIPT. Lines 2-6. 32.

[9] Throughout the testimony Pe Chuy Chip Se (or the English translator) used the word "Head" and "Secretary" interchangeably to refer to the leader of the Security Office.

[10] Throughout the testimony Pe Chuy Chip Se (or the English translator) used the word "Chief" and "Secretary" interchangeably to refer to the leader of the District.

[11] Trial Chamber. Transcript of Trial Proceedings. (12 November 2013). E1/143.1 [hereinafter 12 NOVEMBER TRANSCRIPT. Line 25. 89.

[12] 12 When examined by International Counsel for Nuon Chea, Jasper Pauw, the Witness conceeded that he was unsure whether there were civilian officials amongst the group.

[13] See ISSUE 42.

[14] 12 NOVEMBER TRANSCRIPT Line 19. 4.

[15] The Constitution of the Kingdom of Cambodia 1993 and Subsequent Amendments 2001. (2001). Article 31 stated that, amongst others "The Kingdom of Cambodia shall recognize and respect human rights as stipulated in the United Nations Charter, the Universal Declaration of Human rights, the covenants and conventions related to human rights, women's and children's rights". Article 38 stated that, amongst others "The prosecution, arrest, or detention of any person shall not be done except in accordance with the law". International Covenant on Civil and Political Rights (ICCPR) Article 14 paragraph 3 determines, amongst others: " 3. In the determination of any criminal charge against him, everyone shall be entitled to the following minimum guarantees, in full equality: (d) To be tried in his presence, and to defend himself in person or through legal assistance of his own choosing; to be informed, if he does not have legal assistance, of this right; and to have legal assistance assigned to him, in any case where the interests of justice so require, and without payment by him in any such case if he does not have sufficient means to pay for it; (e) To examine, or have examined, the witnesses against him and to obtain the attendance and examination of witnesses on his behalf under the same conditions as witneasses against him. See United Nations. General Assembly. International Convention on Civil and Political Rights (1966). New York: United Nations.

(Entry into force 23 March 1976.). ICCPR, Karnavas reminded the Chamber, were already incoporated in the Cambodian Constitution and embedded in the Agreement the Establishment Law and the Internal Rules of the ECCC.

[16] During last week's hearing Judge Sylvia Cartwright explained that the Parties were allowed to consult outside experts to scrutinize Dr. Campbell's findings prior to the Doctor's testimony. Ieng Sary's Defense consulted Dr. Harold J. Burstzjan, an expert in forensic psychiatry from Harvard University. Dr. Burstzjan examined the materials submitted from the Defense, which did not include the Accused's medical records prior the most recent examination by Dr. John Campbell, and emailed his preliminary opinion on Dr. Campbell's report.

[17] 12 NOVEMBER TRANSCRIPT. Lines 16-17. 27.

[18] 12 NOVEMBER TRANSCRIPT. Lines 7-10. 31. Smith stated: "However, the issue before Your Honours is he mentally fit to plea? Can he understand the nature of the charges, the course of the proceedings, the details of the evidence? Can he instruct counsel, understand the consequence of the proceedings? Can he testify?".

[19] See The Prosecutor v. Pavle Strugar. IT-01-42-A. ICTY Trial Chamber II. "Decision Re the Defence Motion to Terminate Proceedings" (26 May 2004). The Strugar criteria included the Accused's fitness to plead, understand the nature of the charges, understand the course of the proceedings, understand the details of the evidence, to instruct counsel, understand the consequences of the proceedings, and testify.

[20] The International Prosecutor discredited the findings in the email as were based on incomplete medical data, without ever meeting the Accused.

[21] Smith was referring to the September 2012 examination of Ieng Sary by Dr. Campbell, Dr. Seena Fazel and Dr. Huot Lina as well as the recent examination by Dr. Campbell.

[22] The Prosecutor v. Pavle Strugar. IT-01-42-A. ICTY Appeals Chamber. "Judgment" (17 July 2008). Par 55.

[23] See Trial Chamber. Transcript of Trial Proceedings Trial Day 120 (19 October 2012). E1/135.1. Pg. 40; Lines 7-18.

[24] See Trial Chamber. Transcript of Trial Proceedings. (25 October 2012). E1/139.1. Lines 6-15. 68.

[25] Rochoem Ton alias "Cheam" or "Phy Phuon" was a former high-ranking Ministry of Foreign Affairs cadre who testified before the Chamber from 25 July to 2 August. See CASE 002 KRT TRIAL MONITOR, ISSUE NO. 29, Hearing on Evidence Week 24 (23-26 July); and CASE 002 KRT TRIAL MONITOR, ISSUE NO. 30, Hearing on Evidence Week 25 (30-31 July, 1-2 August 2012).

[26] See CASE 002 KRT TRIAL MONITOR, ISSUE NO. 35, Hearing on Evidence Week 30 (3-6 September 2012).

[27] Pe Chuy Chip Se stated that he was telling the OCIJ investigators that Ta Chong was pressurizing him not to talk in too much details with Henri Locard, because then then he would not be getting more money from him, presumably referring to the fact that there would be no more follow up interviews.

[28] Ieng Sary was identified to being in the holding cell on Monday and on Wednesday he was declared absent. The Greffier however stated that the Accused had waived his right to be present during Pe Chuy Chip Se and Meas Saran's testimony.

[29] Nuon Chea had health complaints on Monday and after a doctor examined him, he was identified as suffering from fatigue and was allowed to observe the proceedings from the holding cell. He continued to be in the holding cell on Wednesday.

[30] Pe Chuy Chip Se testified on Monday and Wednesday this week.